ឆ្នាំទី៧២ លេខ ២៥៣ ខែមិថុនា ឆ្នាំ ២០២២

និពន្ធនាយក :

លោក តាក ស៊ុនអ៊ី

គណៈកម្មការនិពន្ធ

១. លោក ខ្យៃវ ណារី
២. លោក អ៊ីម សុន្ទរៈ
៣. លោក វង្ស សារុំធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
៦. លោក ងួន កុលបុត្រ
៧. លោក មាន សេរីរិត

លេខានិពន្ធ

១. លោក ស្វាយ ភីរុណ
២. លោក ម៉ក់ ឈិន

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័ត

អ្នកថតរូប

១. លោក សុផាត វីរៈមុនី

ចិបិត្រករ

១. លោក ធា សារុំធ

អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥

Address :

No 203 Preah

Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

មាតិកា
Contents

អបអរសាទរខួបលើកទី៧១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ***សម្តេចតេជោ ហ៊ុន សែន*** *: ក្រោមពន្លឺនៃ ....*

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ជំណើរការដោយរលូន និងប្រកបដោយជោគជ័យ....

សម្តេចតេជោ ហ៊ុន សែន *: យើងត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីបើកចំហ និង គាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគី និងពង្រឹង .....*

សម្តេចតេជោ ហ៊ុន សែន *: រ៉ាក់សាំងអាចចាត់ទុកជានិមិត្តរូបនៃសាមគ្គីជាតិ និងឯកភាពជាតិរបស់យើង .....*

សម្តេចតេជោ ហ៊ុន សែន *: សន្តិភាពដែលបានកើតឡើងកន្លងមកនេះ គឺក្រោមការដឹកនាំរបស់គណបក្ស .....*

សម្តេចក្រឡាហោម ស ខេង *: ណែនាំឱ្យអាជ្ញាធរមូលដ្ឋានមានទំនាក់ទំនងល្អ ជាមួយប្រជាពលរដ្ឋ.....*

សម្តេចវិបុលសេនាភក្តី សាយ ឈុំ *: ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស គឺជាកិច្ចការដ៏សំខាន់ និងចាំបាច់រួម .....*

ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត *: គណបក្សប្រជាជនតម្កល់ផលប្រយោជន៍ជាតិ និងប្រជាជនជាធំក្រោមផ្លុងមហា .....*

ក្របមុខ : ទិដ្ឋភាពជំណើរការដោយជោគជ័យការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥

វិចារណកថា : គណបក្សប្រជាជនកម្ពុជា មានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹក ០៣

Editorial : The Cambodian People´s Party Has Ability and Sufficient Capacity to ០៣

- *អត្ថបទនយោបាយ: អត្ថន័យជំធំធេងនៃជោគជ័យរបស់គណបក្សប្រជាជនកម្ពុជាក្នុងការបោះឆ្នោត.. ០៦*
- *លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ២០២២..... ០៩*
- *សេចក្តីថ្លែងការណ៍ របស់គណបក្សប្រជាជនកម្ពុជា ១០*
- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ២៣*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ២៧*
- *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ២៩*
- *ជំរុញការថែទាំស្រូវរដូវវស្សា ខណៈល្បឿននៃការដាំដុះដំណាំស្រូវឆ្នាំនេះ យឺតជាងឆ្នាំមុន ៣០*
- *កំណាព្យ: អម្ប្យូរសត្វឃ្មុំ ..... សំណើច ៣២*

ក្នុងឱកាសជ័យមហានក្ខត្តឫក្សនៃទិវាបុណ្យរំឭកខួបលើកទី ៧១
ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨.៦.១៩៥១-២៨.៦.២០២២)

សម្តេចអគ្គមហាពញាចក្រី
ហេង សំរិន
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ
ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ប្រធានគណបក្សប្រជាជនកម្ពុជា

សម្តេចក្រឡាហោម
ស ខេង
ឧបនាយករដ្ឋមន្ត្រី
និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
អនុប្រធានគណបក្សប្រជាជនកម្ពុជា

សម្តេចវិបុលសេនាភក្តី
សាយ ឈុំ
ប្រធានព្រឹទ្ធសភា
នៃព្រះរាជាណាចក្រកម្ពុជា
អនុប្រធានគណបក្សប្រជាជនកម្ពុជា

សម្តេចពិជ័យសេនា
ទៀ បាញ់
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ
អនុប្រធានគណបក្សប្រជាជនកម្ពុជា

លោកជំទាវកិត្តិសង្គហបណ្ឌិត
ម៉ែន សំអន
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់
ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
អនុប្រធានគណបក្សប្រជាជនកម្ពុជា

យើងខ្ញុំសូមសម្តែងគារវភក្តី និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូន **សម្តេច** មគ្គុទ្ទេសក៍ដ៏ឧត្តុង្គឧត្តមបំផុត នៃប្រជាជាតិកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណ ដើម្បីបុព្វហេតុសង្គ្រោះជាតិ ពីរបបប្រល័យពូជសាសន៍ កសាង និងការពារមាតុភូមិកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាព សង្គម ។

សូមគោរពជូនពរ **សម្តេច** សូមបានប្រកបដោយសុខភាពបរិបូរ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា និងជន្មាយុយឺន យូរ ដើម្បីបន្តដឹកនាំមាតុភូមិ និងប្រជាជនកម្ពុជា ឆ្ពោះទៅរកជោគជ័យធំៗថ្មីៗទៀត ។

គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ទស្សនាវដ្តីប្រជាជន

លោក តាក ស៊ុនអ៊ី

អារម្ភកថា

សូមគោរព សម្តេច ឯកឧត្តម លោកជំទាវ
លោក លោកស្រី ប្រិយមិត្តអ្នកអាន !

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គសេនាមហាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ជានាយករដ្ឋមន្ត្រី បាននិងកំពុងបោះជំហានទៅមុខយ៉ាងស្វាហាប់ ប្រកបដោយក្តីសង្ឃឹមនៅលើមាគ៌ានៃការអភិវឌ្ឍ ក្រោមពន្លឺនៃសុខ-សន្តិភាពដ៏ត្រចេះត្រចង់ ឆ្ពោះទៅកាន់អនាគតដ៏រុងរឿង។ នៅពេលដែលប្រជាជនយើងកំពុងសប្បាយរីករាយជាមួយសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រ ដែលគណបក្សប្រជាជនកម្ពុជាបានសម្រេចជូនជាតិមាតុភូមិ ចាប់តាំងពីក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ មក ពេលនេះប្រជាជនកម្ពុជាទូទាំងប្រទេស ក៏បានចូលរួមអបអរសាទរយ៉ាងក្លៀវក្លា ខួបទី៧១ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨ មិថុនា ១៩៥១- ២៨ មិថុនា ២០២២) ដែលជាព្រឹត្តិការណ៍នយោបាយមួយមានអត្ថន័យយ៉ាងជ្រាលជ្រៅ។ ការប្រារព្ធពិធីនេះ ត្រូវបានធ្វើឡើងក្នុងពេលដែលប្រទេសជាតិយើងទើបនឹងដំណើរការដោយជោគជ័យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ ដែល បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយគណបក្សប្រជាជនកម្ពុជាទទួលបានជ័យជម្នះយ៉ាងធំធេង។ ជោគជ័យនេះក៏ទទួលបានក្នុងខណៈប្រទេសកម្ពុជាគ្រប់គ្រងបានការឆ្លងរាតត្បាតជំងឺកូវីដ-១៩ ការពារបានអាយុជីវិតប្រជាជនមិនឲ្យធ្លាក់ក្នុងជ្រោះមរណៈ រក្សាបានលំនឹងសេដ្ឋកិច្ច និងជីវភាពរស់នៅ និងសម្រេចបានសមិទ្ធផលថ្មីៗបន្តទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមជាមួយនេះ កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាក៏កាន់តែត្រូវបានលើកកម្ពស់ឡើងនៅលើឆាកអន្តរជាតិ ស្របពេលដែលកម្ពុជាកំពុងទទួលតួនាទីជាប្រធានអាស៊ាន និងការត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ នៅឆ្នាំ២០២៣ខាងមុខ។

ទស្សនាវដ្តីប្រជាជន ដែលបានបដិសន្ធិនៅខែមិថុនា ឆ្នាំ២០០១ ហើយដែលពេលនេះ មានអាយុគម្រប់ ២១ឆ្នាំ សូមចូលរួមជាមួយប្រជាជនកម្ពុជា អបអរសាទរខួបលើកទី ៧១ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា និងសូមសម្តែងនូវក្តីសប្បាយរីករាយ ប្រកបដោយមោទនភាពចំពោះសមិទ្ធផលធំៗ ដែលគណបក្សសម្រេចបានក្នុងការដឹកនាំប្រទេសជាតិ គាំទ្រពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ ស្តារ និងកសាងប្រទេសជាតិឡើងវិញពីចំណុចសូន្យ រហូតឈានមកដល់ដំណាក់កាល សន្តិភាព ឯកភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍ នាពេលបច្ចុប្បន្ន។

ក្នុងរយៈពេល ២១ ឆ្នាំកន្លងទៅនេះ **ទស្សនាវដ្តីប្រជាជន** ដែលជាអង្គភាពឃោសនា និងផ្សព្វផ្សាយចំណុះគណៈឃោសនាអប់រំនៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា បានយកអស់ស្មារតីទទួលខុសត្រូវក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវមនសិការវិជ្ជាជីវៈ រួមចំណែកក្នុងការផ្សព្វផ្សាយកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស និងរាជរដ្ឋាភិបាល ឲ្យបានជ្រួតជ្រាបដល់មន្ត្រី សមាជិកគណបក្ស និងមហាជន ព្រមទាំងផ្សព្វផ្សាយអំពីសភាពការណ៍ទូទៅរបស់ប្រទេសជាតិ សកម្មភាពរបស់ថ្នាក់ដឹកនាំគណបក្ស ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគ្រប់ថ្នាក់ គ្រប់ផ្នែក ដែលបានអញ្ជើញចុះមូលដ្ឋានជួយដោះស្រាយបញ្ហានានាជូនប្រជាជន។ **ទស្សនាវដ្តីប្រជាជន** ក៏បានរួមចំណែកបំផុសលើកទឹកចិត្ត និងអប់រំពង្រឹងស្មារតីប្រជាជន ដើម្បីចូលរួមការពាររាល់សមិទ្ធផលនៃសង្គមជាតិ ថែរក្សាសុខសន្តិភាព និងស្ថិរភាពនយោបាយ ការពារឯករាជ្យអធិបតេយ្យជាតិ បូរណភាពទឹកដី លើកកម្ពស់ដំណើរការការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ បំផុស និងលើកទឹកចិត្តប្រជាជនចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ពង្រឹងខឿនការពារសុខភាពរបស់ប្រជាជនកាន់តែរឹងមាំ ព្រមទាំងឆ្លើយតបទៅនឹងការឃោសនាប្រទូសរ៉ាយនានារបស់ពួកអគតិ។ **ទស្សនាវដ្តីប្រជាជន** ក៏បានរួមចំណែកផ្សព្វផ្សាយអំពីកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានលើកកម្ពស់ជាលំដាប់នៅលើឆាកអន្តរជាតិ ជាពិសេស ក្នុងពេលដែលប្រទេសយើងធ្វើជាប្រធានអាស៊ានប្តូរវេនឆ្នាំ២០២២នេះ។

ក្នុងរយៈពេល ២១ឆ្នាំកន្លងទៅនេះ លទ្ធផលដែល **ទស្សនាវដ្តីប្រជាជន** អាចរក្សាបាននិរន្តរភាពនៃការផ្សាយ និងទទួលបានលទ្ធផលដ៏ប្រសើរ គឺអាស្រ័យដោយមានការដឹកនាំណែនាំពីថ្នាក់ដឹកនាំគណបក្ស និងការចូលរួមជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លា ទាំងខាងស្មារតី និងសម្ភារៈពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់។

ចំពោះការគាំទ្រដ៏ថ្លៃថ្លានេះរបស់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី យើងខ្ញុំទាំងអស់គ្នាជាមន្ត្រីបុគ្គលិកនៃ**ទស្សនាវដ្តីប្រជាជន** សូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត និងជឿជាក់ថា នឹងបានទទួលនូវការរួមវិភាគទានដ៏ថ្លៃថ្លានេះបន្តទៀត ដើម្បីធានាបាននូវនិរន្តរភាពនៃការចេញផ្សាយរបស់ទស្សនាវដ្តី។ យើងខ្ញុំនឹងបន្តខិតខំប្រឹងប្រែងបង្កើនសមត្ថភាពរបស់ខ្លួនលើគ្រប់ផ្នែកឲ្យបាន និងកាន់តែប្រសើរ ដើម្បីលើកកម្ពស់ការចេញផ្សាយទស្សនាវដ្តីប្រជាជនឲ្យបានទៀងទាត់ និងប្រកបដោយគុណភាព រួមចំណែកបម្រើវិស័យអប់រំនយោបាយ សតិអារម្មណ៍របស់គណបក្សឲ្យបានកាន់តែប្រសើរឡើង។

នៅក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំសូមគោរពជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមបានប្រកបតែនឹងសេចក្តីសុខ សេចក្តីចម្រើន និងជោគជ័យគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ៕

ដោយសេចក្តីគោរព ពីទស្សនាវដ្តីប្រជាជន

វិចារណកថា EDITORIAL

គណបក្សប្រជាជនកម្ពុជា មានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសង្គមជាតិឲ្យបន្តឈានឆ្ពោះទៅមុខទៀត

The Cambodian People's Party Has Ability and Sufficient Capacity to Advance Nation

ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២២ គឺជាថ្ងៃគម្រប់ខួបទី ៧១ ថ្ងៃបង្កើត **គណបក្សប្រជាជនកម្ពុជា** (២៨ មិថុនា ១៩៥១-២៨ មិថុនា ២០២២) ដែលនៅគ្រាដំបូងមានឈ្មោះថា **"បក្សប្រជាជនបដិវត្តន៍ខ្មែរ"** ។ គណបក្សបានប្រសូត្រចេញពីចលនាតស៊ូស្នេហាជាតិ របស់ប្រជាជនកម្ពុជាទូទាំងប្រទេសក្នុងបុព្វហេតុទាមទារឯករាជ្យពីនឹមអាណានិគមនិយមបារាំងដោយបានធ្វើការតស៊ូព្យុះពារ ឆ្លងកាត់គ្រប់ឧបសគ្គរាប់ម៉ឺន រាប់សែនដំពូក ។

ក្នុងរយៈពេល ៧១ ឆ្នាំ កន្លងទៅនេះ នៅលើកំណាត់ផ្លូវយ៉ាងវែង និងបត់បែនលំបាក់សុគស្មាញនៃប្រវត្តិសាស្ត្រកម្ពុជា ប៉ុន្តែគណបក្សប្រជាជនកម្ពុជា តែងតែស្ថិតនៅរួមសុខរួមទុក្ខជាមួយប្រជាជនគ្រប់កាលៈទេសៈទាំងអស់ ។ គ្មានការលំបាកណាមួយ ដែលគណបក្សប្រជាជនកម្ពុជាពុំធ្លាប់ឆ្លងកាត់នោះទេ ហើយក៏គ្មានឧបសគ្គណាមួយដែលគណបក្សប្រជាជនកម្ពុជា មិនធ្លាប់បានជម្នះនោះដែរ ។ គណបក្សប្រជាជនកម្ពុជា បានធ្វើការប្រមូលផ្តុំកម្លាំងមហាសាមគ្គីជាតិ ធ្វើឲ្យសម្រេចបាននូវសមិទ្ធផលធំៗរាប់មិនអស់ ។ ចាប់ពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ គណបក្សបានរួមចំណែកយ៉ាងធំធេង ជាមួយកម្លាំងជាតិ ក្នុងការតស៊ូប្រឆាំងអាណានិគមនិយមដណ្តើមបានឯករាជ្យទាំងស្រុង និងបានចូលរួមក្នុងការថែរក្សាការពារឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត្យ និងវឌ្ឍនភាពសង្គម។ ក្នុងពេលដែលប្រទេសជាតិធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាម ដោយសារស្នាដៃបនក្បត់ជាតិ លន់ នល់ សិរិមតៈ ពីថ្ងៃទី១៨ មិនា ឆ្នាំ ១៩៧០ ដល់ថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ គណបក្សប្រជាជនកម្ពុជា បានបន្តដឹកនាំធ្វើការតស៊ូ ដើម្បីរំដោះជាតិចេញពីពួក មេដឹកនាំធ្វើរដ្ឋប្រហារ ដែលជាខ្ញុំកញ្ជះដាច់ថ្លៃរបស់ពួកបរទេស ។ ក្រោយពេលដែលប្រទេសជាតិ ត្រូវបានរំដោះហើយ ប្រជាជនទូទាំងប្រទេសសង្ឃឹមថា សង្គ្រាមនឹងត្រូវផុតរលត់ សង្ឃឹមបានឃើញពន្លឺសន្តិភាពរះឡើងជាថ្មីនៅលើមាតុភូមិកម្ពុជា ។ តែផ្ទុយទៅវិញក្តីសង្ឃឹមនេះ បែរជាត្រូវបំផ្លិចបំផ្លាញទៅវិញ តែក្នុងរយៈពេលតែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ។ បនក្បត់ប៉ុល ពត អៀង សារី ខៀវសំផន ឃុបឃិតគ្នា ឆក់ប្លន់សមិទ្ធផលជ័យជម្នះរបស់ប្រជាជនកម្ពុជា បង្កើតឡើងនូវរបបប្រល័យពូជសាសន៍ ក្រោមស្លាកកម្ពុជា ប្រជាធិបតេយ្យ ធ្វើឲ្យប្រជាជនរាប់លាននាក់ ត្រូវបាត់បង់ជីវិត ដោយសារការកាប់សម្លាប់ធ្វើទារុណកម្មបង្អត់អាហារ និងការធ្វើពលកម្មបាក់កម្លាំង ។ របបទាសភាពសម័យថ្មី បានកើតឡើងនៅលើទឹកដីកម្ពុជា ធ្វើឲ្យមាតុភូមិដ៏កំសត់ ដែលទើបងើបរួចពីភ្លើងសង្គ្រាមត្រូវចាប់ជ្រមុជឲ្យលិចយ៉ាងជ្រៅទៅក្នុងផ្លូវកណ្តាលដ៏ក្រហមច្រាលរបស់ប្រជាជនកម្ពុជា ដ៏អភ័ព្វ ។ ជាថ្មីម្តងទៀតគណបក្សប្រជាជនកម្ពុជា បានបន្តដឹកនាំចលនាតស៊ូសង្គ្រោះជាតិ វាយផ្តួលរំលំរបបប្រល័យពូជសាសន៍នេះ ឲ្យវិនាសខ្ទាត់ខ្ទាយនៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ ។ មហាជ័យជម្នះនេះ បានបិទទំព័រសកវាជដ៏ខ្មៅងងឹតក្រៀមក្រំដោយសោកនាដកម្មនៃកម្ពុជា ហើយបានបើកឡើងនូវទំព័រសកវាជថ្មី គឺឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ។ ក្នុងរយៈពេល ៤៣ ឆ្នាំកន្លងមកនេះ គណបក្សបានដឹកនាំឲ្យ ទទួលបានជ័យជម្នះក្នុងការទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ការស្តារ និងកសាងសេដ្ឋកិច្ចសង្គមឡើងវិញ ចាប់ពីលេខសូន្យឲ្យមានការរីកចម្រើនយ៉ាងលឿន រហូត

June 28, 2022 is the 71st founding anniversary of the Cambodian People's Party (June 28, 1951 - June 28, 2022), which was originally called the "Khmer Revolutionary People's Party". The party was born out of the patriotic movement of the Cambodian people throughout the country in the cause of independence from the yoke of the French colonialism, struggling to overcome tens of thousands of obstacles.

For the past 71 years, on the long and winding road, the complexities of Cambodian history, the Cambodian People's Party has always been in solidarity with the people in all circumstances. There are no difficulties that the CPP has never gone through, and there are no obstacles that the CPP has never overcome. The Cambodian People's Party has mobilized the forces of national unity to achieve countless great achievements. From 1953 to 1970, the party contributed greatly to the national forces in the struggle against colonialism, gained full independence and participated in the preservation of independence, peace, freedom, democracy, neutrality and social progress.

As the nation fell into the flames of war due to the treason by Lon Nol and Sirik Matak from March 18, 1970 to April 17, 1975, the CPP continued to lead the struggle for national liberation from those Coup d'état leaders, who served foreigners' interests. After the nation was liberated, people all over the country hoped that the war would end, wishing to see the light of peace shine again on the motherland of Cambodia. On the contrary, this hope was shattered in the blink of an eye. The treacherous Pol Pot, Ieng Sary and Khieu Samphan, conspired to rob the Cambodian people of their achievements, establishing a genocidal regime under the banner of Democratic Kampuchea, killing millions of people through massacres, torture, starvation and hard labor. A new era of slavery took place on Cambodian soil, leaving the poor motherland, which had just recovered from the fires of war, sink deep into the pool of blood of the miserable Cambodian people.

Once again, the CPP continued to lead the struggle movement, for national salvation overthrowing the genocidal regime on January 7, 1979. This great victory closed the pages of the tragic dark era of Cambodia and ushered in a new era of independence, freedom, democracy and social progress. For the past 43 years, the party has led the victory in preventing the return of the genocidal regime, rehabilitating and rebuilding the socio-economy from zero to rapid growth until now. The Party is a strong and vibrant force in defending the Constitution, defending the monarchy, defending independence, sovereignty,

*មកដល់បច្ចុប្បន្ន ។ គណបក្សគឺជាបង្អែកដ៏រឹងមាំ ជាកម្លាំងប្រកបដោយថាមពលរស់រវើកក្នុងការការពារដួងមន្ទុញ្ញការពាររបបរាជានិយមការពារឯករាជ្យអធិបតេយ្យ បូរណភាពទឹកដីថែរក្សាសន្តិភាពស្ថិរភាពនយោបាយ និងការអនុវត្តដោយជោគជ័យនូវដំណើរការប្រជាធិបតេយ្យ ភារូបនីយកម្ម ដែលធ្វើឲ្យការប្រព្រឹត្តទៅនូវការបោះឆ្នោត ទាំងការបោះឆ្នោតថ្នាក់ជាតិ និងការបោះឆ្នោតថ្នាក់ក្រោមជាតិ មានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវស្របតាមច្បាប់កំណត់ ។ គណបក្ស បានធ្វើជាស្នូលនៃការបង្រួបបង្រួមជាតិ ឯកភាពជាតិ បង្កើតបានសុខសន្តិភាពក្នុងក្របខណ្ឌទូទាំងប្រទេស តាមរយៈជោគជ័យនៃនយោបាយឈ្នះ ឈ្នះ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។ គណបក្សបានដឹកនាំអនុវត្តកំណែទម្រង់រដ្ឋដ៏ទូលំទូលាយ និងស៊ីជម្រៅប្រកបដោយផ្លែផ្កា ដើម្បីលើកកម្ពស់ភាពសុខដុមរមនា ជូនប្រជាជនកម្ពុជា ។ សេដ្ឋកិច្ចកម្ពុជា សម្រេចកំណើនយ៉ាងឆាប់រហ័ស ដោយរក្សាកំណើនខ្ពស់ជាមធ្យម ៧,៧% ក្នុងរយៈពេល ២ ទស្សវត្ស ហើយត្រូវបានចាត់ទុកថា ជាប្រទេស ឯកទគ្គករកំណើនដោយធនាគារពិភពលោក និងជាខ្លាសេដ្ឋកិច្ចមួយនៅអាស៊ី ។ ប៉ុន្តែចាប់ពីឆ្នាំ ២០១៩ មកដល់បច្ចុប្បន្ន អាស្រ័យដោយការរាតត្បាតនៃជំងឺកូវីដ-១៩ បានធ្វើឲ្យប៉ះពាល់ទៅដល់ដំណើរអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បានឆ្លើយតបជ័យានប្រសិទ្ធភាពទៅនឹងវិបត្តិនៃជំងឺកូវីដ-១៩ ដោយការអនុវត្តគ្រប់យុទ្ធសាស្ត្រ ដែលធ្វើឲ្យកម្ពុជា ក្លាយទៅជាប្រទេសមួយ ក្នុងចំណោមប្រទេសក្នុងតំបន់ និងលើពិភពលោក ដែលសម្រេចបាននូវការចាក់វ៉ាក់សាំងជូនប្រជាជនបានខ្ពស់ជាងគេ និងធ្វើឲ្យកម្ពុជា សម្រេចបាននូវភាពស៊ាំសហគមន៍នៅត្រឹមដំណាច់ខែតុលា ឆ្នាំ ២០២១ និងការឈានទៅបើកដំណើរការសកម្មភាពសង្គមសេដ្ឋកិច្ចពេញលេញឡើងវិញ នៅថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២១ នៅក្នុងបរិបទនៃការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ក្នុងភាពរឹងមាំ និងការវិលត្រឡប់ទៅរកមាគ៌ានៃកំណើនជាសក្តានុពល និងអភិវឌ្ឍប្រកបដោយចីរភាព ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣" ប្រកបដោយប្រសិទ្ធភាព ដែលរហូតមកដល់ពេលនេះ កំពុងដំណើរការទៅ ជាប្រក្រតី និងប្រកបដោយផ្លែផ្កា ។ អាស្រ័យដោយមានការគ្រប់គ្រងបានល្អ ដែលធ្វើឲ្យប្រទេសជាតិយើងបានស្ទុះងើបចេញផុតពីការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានសម្រេចបើកប្រទេសឡើងវិញលើគ្រប់វិស័យ បានធ្វើឲ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ធ្វើការព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា ប្រកបដោយភាពវិជ្ជមាន និងសុទិដ្ឋិនិយមខ្ពស់ ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ IMF បានធ្វើការព្យាករណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២២ នឹងសម្រេចបានក្នុងអត្រា ៥,១% និងឆ្នាំ២០២៣ មានកំណើនក្នុងអត្រា ៦,២% ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញនៅកម្រិតប៉ាន់ស្មាន ៣,០% នៅឆ្នាំ២០២១ បន្ទាប់ពីមានកំណើនអវិជ្ជមាន ៣,១% នៅឆ្នាំ២០២០ ។ កំណើនសេដ្ឋកិច្ចកម្ពុជានឹងសម្រេចបានក្នុងកម្រិត ៥,៣% ក្នុងឆ្នាំ២០២២ និង ៦,៥% ក្នុងឆ្នាំ២០២៣ ។ ធនាគារពិភពលោកព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២២ ស្ថិតក្នុងរង្វង់ ៤,៥% និងឆ្នាំ២០២៣ កើនឡើង ៥,៨% ។ ដោយឡែក រាជរដ្ឋាភិបាលកម្ពុជាបានព្យាករណ៍ថា ដោយសារវិបត្តិនៃសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន ការព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២២ ស្ថិតក្នុងរង្វង់ ៥,២% ។*

ក្នុងរយៈពេល ៤ ខែដើមឆ្នាំ ២០២២ ចំណូលពន្ធគយសម្រេចបាន ៨១៧,៩លានដុល្លារស្មើនឹង ៣១% នៃផែនការច្បាប់ថវិកាជាតិ ចំណូលពន្ធដា សម្រេចបាន ១.៥០១,៥៦ លានដុល្លារ ស្មើនឹង ៥៣,២៧% នៃ

territorial integrity, and maintaining peace, political stability and the successful implementation of the democratization process, whereas national and sub-national elections are free, fair and just in accordance with the law. The party has been the core of national reconciliation and unity, created peace in the framework of the whole country through the success of the win-win policy architecture and engineered bu Samdech Akka Moha Sena Padei Techo Hun Sen.

The party has led a comprehensive and in-depth state of fruitful reforms to promote harmony among the Cambodian people. Cambodia's economy has grown rapidly, maintaining an average growth rate of 7.7% over two decades, and is considered by the World Bank as record-breaking growth country and one of Asia's economic tigers. However, from 2019 to the present, due to the outbreak of Covid-19, it has affected Cambodia's socio-economic development. The Royal Government of Cambodia, under the leadership of the Cambodian People's Party, has effectively responded to the Covid-19 crisis by implementing all strategies to make Cambodia one of the most successful countries in the region and the world, where the highest number of population are vaccinated making Cambodia achieve community immunity by the end of October 2021 and allowing re-launch full socio-economic activities on November 1, 2021 in the context of living with Covid-19 in a new normal trajectory in resilience and returning to the path of potential growth and sustainable development.

To achieve this goal, the Royal Government of Cambodia has launched its "Strategic Framework and Program to Rehabilitate and Stimulate Cambodia's Economic Growth in Living with Covid-19 in the New Normal Way for 2021-2023," which is currently being currently and fruitfully implemented. Thank to good governance that has helped our country recover from the Covid-19 epidemic, the Royal Government decided to reopen the country in all areas, prompting positive and optimistic forecasts by major international financial institutions on Cambodia's economic growth. The International Monetary Fund (IMF) has forecast that Cambodia's economic growth for 2022 will be at 5.1% and for 2023 at 6.2%. The Asian Development Bank (ADB) has forecast that Cambodia's economic growth will recover to an estimated 3.0% in 2021, after a negative 3.1% growth in 2020. Cambodia's economic growth will reach 5.3% in 2022 and 6.5% in 2023. The World Bank forecasts that Cambodia's economic growth for 2022 will be around 4.5% and for 2023 by 5.8%. Separately, the Royal Government of Cambodia has forecast that due to the crisis of the Russian-Ukrainian war, the forecast for Cambodia's economic growth for 2022 is around 5.2%.

In the first four months of 2022, customs revenue reached US$ 817.9 million, equivalent to 31% of the national budget law plan, while tax revenue reached US$ 1,501.56 million, equivalent to 53.27% of the budget plan. Cambodia's international trade volume totaled 17.6 billion US dollars, up 2.3 billion US dollars from the same

ផែនការច្បាប់ថវិកា ។ ទំហំពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា មានទឹកប្រាក់សរុប ១៧,៦ពាន់លានដុល្លារ កើនឡើង ២,៣ ពាន់លានដុល្លារធៀបរយៈពេលដូចគ្នា ឆ្នាំ ២០២១ ក្នុងនោះការនាំចេញមានទឹកប្រាក់សរុប ៧,៦ពាន់លានដុល្លារ កើនឡើង ៣២,១% ឯការនាំចូលមានទឹកប្រាក់ ១០ ពាន់លានដុល្លារកើនឡើង ៥,៤% ធៀបរយៈពេលដូចគ្នា ឆ្នាំមុន ។ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា បានអនុម័តគម្រោងវិនិយោគចំនួន ៨០ គម្រោង ដែលមានទុនវិនិយោគប្រមាណ ជាង ២.៧០០លានដុល្លារ បង្កើតការងារថ្មីបាន ៥៩.៣១៦កន្លែង ។ ជាមួយគ្នានេះ ដំណើរការអនុវត្តប្រជាធិបតេយ្យ សេរីពហុបក្ស ក៏កំពុងប្រព្រឹត្តទៅជាប្រក្រតី ។ ជាក់ស្តែង នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា កន្លងទៅនេះ មានគណបក្សនយោបាយចំនួន ១៧ បានចូលរួម ។ គណបក្សប្រជាជនកម្ពុជា បានទទួលជ័យជម្នះភ្លូកទឹកភ្លូកដី ដែលបានឆ្លុះបញ្ចាំងឲ្យឃើញអំពីភាពត្រឹមត្រូវនៃគោលនយោបាយរបស់គណបក្ស ការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ថ្នាក់ដឹកនាំគណបក្ស ដែលបានគិតគូ ការពារ និងលើកកម្ពស់ផលប្រយោជន៍របស់ប្រជាជន ហើយប្រជាជនគ្រប់ៗរូបត្រូវការដាច់ខាតនូវសុខសន្តិភាព និងការអភិវឌ្ឍ ។ តាមរយៈជោគជ័យដ៏ធំធេងនេះ ក៏បង្កបាននូវភាពអនុគ្រោះ និងប្រៀបលើសលប់របស់គណបក្សប្រជាជនកម្ពុជា ក្នុងដំណើរឈានឆ្ពោះទៅដណ្តើមជ័យជម្នះ នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ខាងមុខនេះទៀត ។ តាមរយៈនេះបានបង្ហាញថា មានតែគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ ដែលជាក្តីសង្ឃឹមតែមួយគត់របស់ប្រជាជនកម្ពុជា ជាគណបក្សដែលមានសមត្ថភាព រឹងមាំក្នុងការដឹកនាំសង្គមជាតិឲ្យបន្តឈានឡើងលើមាគ៌ាសន្តិភាពប្រជាធិបតេយ្យ និងអភិវឌ្ឍ ។

អបអរខួបទី៧១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា គណបក្សគ្រប់ថ្នាក់ សមាជិកគណបក្សទាំងអស់ត្រូវភ្ជាប់ជាប់ភារកិច្ចរួម ជាយុទ្ធសាស្ត្ររបស់គណបក្សគឺ "ពង្រឹងកម្លាំងមហាសាមគ្គីប្រជាជាតិការពារឯករាជ្យអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ថែរក្សាសន្តិភាពនិងរាល់សមិទ្ធផលនៃសង្គមជាតិឲ្យបានរឹងមាំ ស្ថិតស្ថេរ, លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ និងបន្តជំរុញដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព ឈានទៅសម្រេចចក្ខុវិស័យរយៈពេលមធ្យម និងរយៈពេលវែងរបស់គណបក្ស ។ពង្រឹងការផ្សារភ្ជាប់ជាមួយប្រជាជន ខិតខំលើកកម្ពស់ជីវភាពប្រជាជន និងចលនាប្រជាជនចូលរួមអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ព្រមទាំងរាំងស្ទាក់រាល់ឧបាយកល និងសកម្មភាពពីគ្រប់មជ្ឈដ្ឋានទាំងក្នុង និងក្រៅប្រទេស ដែលប៉ុនប៉ងបំផ្លាញរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ជាពិសេសតាមរយៈបដិវត្តន៍ពណ៌ ។ បន្តកសាង ពង្រឹងគណបក្សឲ្យរឹងមាំទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ដើម្បីធានាការដឹកនាំសម្រេចរាល់ភារកិច្ចនយោបាយក្នុងដំណាក់កាលថ្មី ។ យកចិត្តទុកដាក់គ្រប់គ្រងកសាងពង្រឹងជួរមន្ត្រីគណបក្សឲ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ ទាំងសមត្ថភាពបំពេញការងារ ទាំងគុណធម៌ ដែលធានានូវការអនុវត្តគោលនយោបាយរបស់គណបក្សប្រកបដោយប្រសិទ្ធភាព, ការផ្សារភ្ជាប់រវាងគណបក្ស និងមហាជន និងធានាដល់ការបន្តវេន ។ ប្តេជ្ញារក្សាប្រៀបខ្លាំង ប្រៀបឈ្នះរបស់គណបក្សក្នុងគ្រប់ការបោះឆ្នោតខាងមុខ ជាពិសេសការបោះឆ្នោតជាតិនីតិកាលទី ៧ ឆ្នាំ ២០២៣ ។

ទស្សនាវដ្តីប្រជាជន

period in 2021, of which exports totaled 7.6 billion US dollars, up 32 billion US dollars. Imports amounted to 10 billion US dollars, up 5.4 percent from the same period last year. The Council for the Development of Cambodia has approved 80 investment projects with an investment of more than US$ 2.7 billion, creating 59,316 new jobs.

At the same time, the process of implementing multi-party liberal democracy is proceeding normally. In fact, in the 5th commune/Sangkat council election on June 5, 17 political parties participated. The Cambodian People's Party (CPP) has won a landslide victory that reflects the correctness of the party's policies, the wise leadership of the party leaders who have considered, protected and promoted the interests of the people and all people are in absolute need of peace and development. This great success also created favor and superiority of the Cambodian People's Party in the path to victory in the upcoming 7th National Assembly election in 2023. This shows that only the Cambodian People's Party, the only hope of the Cambodian people, is a party that has a strong ability to lead the society/nation for further advancements on the path of peace, democracy and development.

To celebrate the 71st founding anniversary of the Cambodian People's Party, all levels of party members must adhere to the party's common strategic tasks of "strengthening the unity of the nation, defending the independence, sovereignty and territorial integrity of Cambodia, and maintaining peace and all achievements of society/nation." Strengthen and promote democracy and the rule of law, and continue to promote the process of sustainable socio-economic development to achieve the party's medium- and long-term vision. Strengthen and stay attached with the people while making efforts uplift the people's living condition and mobilizing people to participate in the implementation of the political platform and fourth phase Royal Government's Rectangular strategy, as well as prevention of all tactics and activities from all circles, both inside and outside the country, that attempt to destroy the Royal Government and the Cambodian People's Party, especially through the color revolution.

Continue to build and strengthen the party in terms of politics, mentality and organization to ensure the leadership accomplishes all political tasks in the new phase. Give more attention to managing, building and strengthening the ranks of party officials with qualification in terms of performance and virtues, which ensures the effective implementation of party policies, linking between the party and the masses, and ensuring the succession of succession. The Party is committed to maintaining the strength and advantage of the party in all upcoming elections, especially the 7th National Election 2023./.

THE PRACHEACHUN MAGAZINE

សម្តេចតេជោ ហ៊ុន សែន ៖ មន្ត្រីត្រូវរំលឹកខ្លួនឯងឱ្យជាប់ជាប្រចាំថា ខ្លួនជាអ្នកបម្រើប្រជាពលរដ្ឋមិនមែនជាចៅហ្វាយពលរដ្ឋនោះទេ ហើយគោលដៅរបស់ខ្លួន គឺការបម្រើប្រជាពលរដ្ឋដោយស្មោះត្រង់

អត្ថន័យដ៏ធំធេងនៃជោគជ័យរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៥ ដែលបានប្រព្រឹត្ត ទៅកាលពីថ្ងៃទី ៥ ខែមិថុនា កន្លងទៅនេះ បានដំណើរការទៅដោយជោគជ័យ ។ គណបក្សនយោបាយចំនួន ១៧ បានចូលរួមធ្វើការប្រកួតប្រជែង ដោយបានដាក់បេក្ខជនសរុបចំនួន ៨៦.០៩២នាក់ (ស្ត្រី ២៧.៨១៣នាក់)។ នៅក្នុងនោះ គណបក្សប្រជាជនកម្ពុជាក៏បានចូលរួមប្រកួតប្រជែងប្រកបដោយភាពភ្លៀវភ្លា និងស្វាហាប់យ៉ាងក្រៃលែងជាមួយនឹងប្រៀបឧត្តមភាព និងក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំចំពោះជ័យជម្នះ។ គណបក្សប្រជាជន កម្ពុជា បានដាក់បេក្ខជននៅ ២៥ លើ ២៥ រាជធានី ខេត្ត តាមឃុំ សង្កាត់ ចំនួន ១.៦៥២ លើ ១៦៥២ ឃុំ សង្កាត់ ដោយមានបេក្ខជនសរុប ២៨.០០៨នាក់ (ស្រី ៧.២៦២នាក់) ។

ជោគជ័យនេះបានឆ្លុះបញ្ចាំងឲ្យឃើញនូវអត្ថន័យដ៏សំខាន់មួយចំនួន នោះគឺ៖ កម្ពុជាមានសន្តិភាពពេញលេញ និងរក្សាបានសន្តិសុខសណ្តាប់ធ្នាប់សង្គមបានល្អប្រសើរ ក្នុងក្របខណ្ឌទូទាំងប្រទេស បង្កលក្ខណៈឲ្យប្រជាជនបានទៅបោះឆ្នោត ក្នុងបរិយាកាសអព្យាក្រឹត សេរី គ្មានការគំរាមកំហែង និងរំលោភបំពានណាមួយឡើយ ។ប្រជាជនកម្ពុជាកាន់តែមានការយល់ដឹង និងបានធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ខ្លួនក្នុងការគាំទ្រថែរក្សាការពារសន្តិភាព និងការបន្តការអភិវឌ្ឍ ។ ជំណើរីកលូតលាស់កាន់តែរឹងមាំនៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។ បណ្តាគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតសុទ្ធតែទទួលបានសំឡេងគាំទ្រ ទោះតិច ឬច្រើន ហើយក្នុងនោះមានគណបក្សនយោបាយមួយចំនួន បានទទួលអសនៈនៅក្រុមប្រឹក្សា ឃុំ សង្កាត់ ។ ធ្វើឲ្យបរាជ័យនូវឧបាយកលរបស់ក្រុមប្រឆាំងជ្រុលនិយម ដែលតែងតែព្យាយាមបំផ្លិចបំផ្លាញដំណើរការនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ បំផ្លាញសុខសន្តិភាព ជីវភាពរស់នៅដ៏សុខក្សេមក្សាន្តរបស់ប្រជាជន និងទប់ស្កាត់ដំណើរការអភិវឌ្ឍនៅកម្ពុជា ។ គណបក្សប្រជាជនកម្ពុជាកាន់តែបង្កើនបានប្រៀបខ្លាំង ប្រៀបឈ្នះ និងឧត្តមភាពដើម្បីដណ្តើមជ័យជម្នះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ខាងមុខនេះ ។

ជោគជ័យដែលគណបក្សប្រជាជនកម្ពុជា ទទួលបាននៅពេលនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ ។ ក្នុងរយៈពេលជាង ៤០ឆ្នាំ កន្លងមក គណបក្សបានបង្កើតនូវសមិទ្ធផលធំៗជាច្រើនដែលជាមរតកប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាបំផុតនោះគឺ ការសង្គ្រោះអាយុជីវិតប្រជាជនពីរបបប្រល័យពូជសាសន៍ នៅថ្ងៃទី ៧ ខែ មករា ឆ្នាំ១៩៧៩ ការខិតខំស្វះស្វែងបង្កើតឲ្យមានការបង្រួបបង្រួមជាតិ ការឯកភាពជាតិ ឯកភាពទឹកដីជាពិសេសការរំលត់ភ្លើងសង្គ្រាម បង្កើតបាននូវសុខសន្តិភាព តាមរយៈនយោបាយ ឈ្នះ ឈ្នះ របស់**សម្តេចតេជោ ហ៊ុន សែន** នៅចុងឆ្នាំ១៩៩៨ ធ្វើឲ្យកម្ពុជាមានឱកាសអភិវឌ្ឍន៍ប្រទេសក្នុងល្បឿនមួយដ៏លឿន រហូតមកដល់សព្វថ្ងៃ និងការដណ្តើមបានជោគជ័យលើសមរភូមិប្រយុទ្ធប្រឆាំងជំងឺកូវីដ-19 បញ្ចៀសប្រទេសឲ្យរួចពីគ្រោះមហន្តរាយ បញ្ចៀសអាយុជីវិតប្រជាជនឲ្យផុតពីជ្រោះមរណៈ បង្កលទ្ធភាពឈានដល់ការបើកប្រទេសឡើងវិញលើគ្រប់វិស័យ ។ គ្រប់កាលៈទេសៈទាំងអស់ មិនថា ស្ថិតក្នុងស្ថានភាពងាយស្រួលឬលំបាកលំបិនយ៉ាងណា គណបក្សប្រជាជនកម្ពុជាតែងផ្សារភ្ជាប់ខ្លួនជាមួយប្រជាជន និងជួយដោះស្រាយនូវរាល់ឧបសគ្គក្នុងស្មារតីលើកកម្ពស់ផលប្រយោជន៍ប្រជាជនជានិច្ច ។ គណបក្សប្រជាជនកម្ពុជាជាបង្អែកដ៏រឹងមាំតែមួយគត់និងជាក្តីសង្ឃឹមរបស់ប្រជាជន ។ គណបក្សមានថ្នាក់ដឹកនាំដែលមានកិត្យានុភាពមានសមត្ថភាពមានទឹកចិត្តគោរពស្រឡាញ់ប្រជាជន ជាពិសេសគឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺជាស្នូលរបស់គណបក្ស និងជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា ដែលបានដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃអង់អាច សម្រេចបានជោគជ័យដ៏ត្រចះត្រចង់បំផុតជូនជាតិមាតុភូមិ និងប្រជាជន ។ ជោគជ័យរបស់គណបក្សប្រជាជនកម្ពុជា កាន់តែបង្កើនបាននូវប្រៀប និងឧត្តមភាព ដើម្បីដណ្តើមជ័យជម្នះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ខាងមុខនេះ ។

មជ្ឈដ្ឋានអគតិ និងពួកប្រឆាំងផ្តាច់មុខ បានធ្វើការវាយប្រហារដោយចោទប្រកាន់ថា ដំណើរការបោះឆ្នោតស្ថិតក្រោមការកៀបសង្កត់ក្នុងបរិយាកាសលំហប្រជាធិបតេយ្យតូចចង្អៀត ។ នៅពេលដែលការបោះឆ្នោតមិនទាន់ទាំងប្រព្រឹត្តទៅផង ពួកគេបានបដិសេធន៍លទ្ធផលជាមុនរួចស្រេចទៅហើយ ហើយនៅពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាសលទ្ធផលបឋមពួកគេបានចោទប្រកាន់ទាំងងើល ថាមានការលួចបន្លំសន្លឹកឆ្នោត ក្នុងបំណងធ្វើឲ្យស្រអាប់ដល់ដំណើរការនៃការបោះឆ្នោត និងបំភាន់សាធារណៈមតិឲ្យមានការយល់ច្រលំដែលនេះជាឧបាកលដដែលៗ ប្រកបដោយភាពពុតត្បុតដ៏អាក្រក់បំផុត ដូចដែលពួកគេធ្លាប់បានធ្វើគ្រប់ការបោះឆ្នោតទាំងអស់ ។ ប៉ុន្តែពួកនេះក៏កំពុងប្រឈមនឹងវិធានការផ្លូវច្បាប់ដោយមិនមានការលើកលែងឡើយ ដើម្បីផ្តល់យុត្តិធម៌ដល់អ្នករងគ្រោះ ដែលទទួលរងការចោទប្រកាន់នេះ ។

អ្នកសង្កេតការណ៍អន្តរជាតិ សុទ្ធតែបានវាយតម្លៃខ្ពស់អំពីដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ដោយបានបញ្ជាក់ថា ការបោះឆ្នោតនេះបានប្រព្រឹត្តិទៅប្រកបដោយសមធម៌ទៅតាមក្បួនច្បាប់អន្តរជាតិ និងបានសំដែងការកោតសរសើរដល់អ្នកទាំងឡាយណា ដែលបានជួយឱ្យការបោះឆ្នោតនេះទទួលបានជោគជ័យ ព្រមទាំងបានកោតសរសើរជាពិសេសបន្ទាប់ពីគ្រាដ៏លំបាកដែលប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នាពេលកន្លងមក ។ អ្នកសង្កេតការណ៍ទាំងនេះ ក៏បានសម្តែងការអបអរសាទរចំពោះប្រជាជនកម្ពុជា ដែលបានចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត ហើយសូមជូនពរឲ្យប្រទេសកម្ពុជាទទួលបានជោគ ជ័យគ្រប់បែបយ៉ាងក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនិងការអភិវឌ្ឍន៍របស់ខ្លួន ។ជោគជ័យនៃការបោះឆ្នោត ឆ្នាំ២០២២ គឺជាជំហានដ៏សំខាន់មួយទៀត ក្នុងការជំរុញកំណែទម្រង់ដែលកំពុងបន្តរបស់ព្រះរាជាណាចក្រ ដើម្បីសម្រេចបាននូវសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋចំពោះសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ ។

នៅពេលដ៏ខ្លីខាងមុខ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទើបបានដាប់ឆ្នោតនឹងត្រូវចូលទទួលភារកិច្ចរបស់ខ្លួន ដើម្បីបម្រើប្រជាជនដែលជាម្ចាស់ឆ្នោត បន្តធ្វើការអភិវឌ្ឍមូលដ្ឋានឲ្យកាន់តែមានការរីកលូតលាស់ថ្មីទៀត ។ លើមូលដ្ឋាននេះ គណបក្សគ្រប់ថ្នាក់គ្រប់ផ្នែក ក្រុមការងារគណបក្សចុះជួយមូលដ្ឋាន សកម្មជនគណបក្ស ត្រូវខិតខំភ្ជាប់ឲ្យជាប់ និងជំរុញការអប់រំ ផ្សព្វផ្សាយគោលការណ៍ គោលនយោបាយនានារបស់គណបក្ស និងរាជរដ្ឋាភិបាលឲ្យបានជ្រួតជ្រាបចូលជ្រៅដល់ស្រទាប់ប្រជាជន មហាជនលើកកម្ពស់ភាពជាម្ចាស់របស់ប្រជាជន បង្កើនជំនឿទុកចិត្ត និងក្តីសង្ឃឹមរបស់ប្រជាជនមកលើការដឹកនាំរបស់គណបក្ស ។ខិតខំពង្រឹងឆ្លងឯកភាព និងសាមគ្គីភាពផ្ទៃក្នុងឲ្យកាន់តែរឹងមាំ ពុះពារអនុវត្តឲ្យបានរាល់ភារកិច្ចនយោបាយក្នុងដំណាក់កាលថ្មី ដើម្បីពង្រីកប្រៀបខ្លាំង ប្រៀបឈ្នះរបស់គណបក្សនាពេលខាងមុខនេះ ៕

អបអរសាទរខួបលើកទី ៧១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា

សម្តេចតេជោ ហ៊ុន សែន ៖ ក្រោមពន្លឺនៃសន្តិភាព ប្រជាជនកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរធំៗ ជាវិជ្ជមានប្រកបដោយមោទនភាព

គណ:អធិបតីអញ្ជើញចូលរួមមីទ្ទីញរំពឹកខួបលើកទី ៧១ឆ្នាំ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា

នៅព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ នេះ គណបក្សប្រជាជនកម្ពុជា បានប្រារព្ធមីទ្ទីញរំពឹកខួបលើកទី ៧១ឆ្នាំ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្ស និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានកិត្តិយសគណបក្ស និងជាប្រធានរដ្ឋសភាព្រមទាំងសម្តេចឯកឧត្តមលោកជំទាវជាអនុប្រធានគណបក្ស សមាជិក សមាជិកា គណ:អចិន្ត្រៃយ៍ គណ:កម្មាធិការកណ្តាល សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំគណបក្ស ក្រសួង មន្ទីរ ស្ថាប័ន និងបណ្តាអង្គទូតនានា ព្រមទាំងសមាជិក សមាជិកាគណបក្ស ដែលបានអញ្ជើញចូលរួមអង្គមីទ្ទីញ សរុបចំនួនជិត ៦០០០នាក់ នៅទីស្នាក់ការកណ្តាលគណបក្ស (**វិមាន ៧មករា**) ។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្ស ប្រជាជនកម្ពុជា ក៏បានអញ្ជើញចុះហត្ថលេខានៅលើសិលាចារឹក វិមាន ៧មករា ផងដែរ ។

នៅក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញថ្លែងសុន្ទរកថា ដោយបានរំពឹកឡើងវិញអំពីថ្ងៃបដិសន្ធិដំបូង បុព្វហេតុ និងឧត្តមគតិរបស់គណបក្ស ដើម្បីកសាង និងការពារប្រទេសកម្ពុជា ឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា៖ "រយ:ពេល ៧១ឆ្នាំមកនេះ កម្ពុជាបានឆ្លងកាត់ដំណាក់កាលជាប្រវត្តិសាស្ត្រយ៉ាងច្រើន ទាំងដំណាក់កាលប្រកបដោយមោទនភាពផង ទាំងដំណាក់កាលប្រកបដោយភាពបត់បែនលំបាកស្មុគស្មាញ និងគ្រោះថ្នាក់ជាទីបំផុតផង។ ប៉ុន្តែទោះបីស្ថិតក្នុងកាល:ទេស:ណាក្តីក៏គណបក្សប្រជាជនកម្ពុជានៅតែរក្សាខ្ជាប់នូវគោលបំណង និងឧត្តមគតិរបស់ខ្លួន **ដើម្បីកសាង និងការពារប្រទេសកម្ពុជាមួយឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម**។ ពេលប្រទេសជាតិត្រូវធ្លាក់ទៅក្នុងគ្រោះមហន្តរាយដែលរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបង្កឡើង មានតែសមាជិកគណបក្សប្រជាជនកម្ពុជាដ៏បរិសុទ្ធដែលស្មោះត្រង់នឹងគោលបំណង និងឧត្តមគតិរបស់គណបក្សប៉ុណ្ណោះ ដែលបានក្រោកឈរ ឡើងធ្វើការតស៊ូ និងប្រមូលផ្តុំរាល់កម្លាំងស្នេហាជាតិ បង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីប្រយុទ្ធផ្តួលរំលំរបបដ៏យង់ឃ្នងនេះរហូតទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រនៅ **ថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩** ដែលបានសង្គ្រោះជាតិឱ្យរស់រានមានជីវិតឡើងវិញទាន់ពេលវេលា នាំយកសិទ្ធិសេរីភាពដែលត្រូវបាត់បង់ទាំងស្រុងក្នុងរបបប៉ុល ពត មកជូនប្រជាជនវិញ បញ្ចប់សករាជដ៏ខ្មៅងងឹតបំផុត ហើយបើកឡើងនូវសករាជថ្មីរបស់កម្ពុជាប្រកបដោយពន្លឺ និងក្តីសង្ឃឹម។ ប្រជាជនកម្ពុជា ទាំងអ្នកធ្លាប់រងទុក្ខវេទនាក្នុងរបបប្រល័យ ពូជសាសន៍ក៏ដូចយុវវ័យជំនាន់ក្រោយតែងចងចាំជានិច្ចនូវអត្ថន័យដ៏ធំធេងនៃជ័យជម្នះជាប្រវត្តិសាស្ត្រនេះ ដែលធ្វើឱ្យយើងមានអ្វីៗនៅថ្ងៃនេះ។ ព្រមជាមួយនេះលើមូលដ្ឋានជ័យជម្នះ ៧មករា បក្សប្រជាជនបដិវត្តន៍ខ្មែរក៏ត្រូវបានកសាងឡើងវិញដោយមានឈ្មោះថា **បក្សប្រជាជនបដិវត្តន៍កម្ពុជា** និងបន្ទាប់មកត្រូវបានប្តូរឈ្មោះថា **គណបក្សប្រជាជនកម្ពុជា** ដើម្បីធានាការដឹកនាំប្រទេសក្នុងដំណាក់កាលថ្មី។

ក្រោយថ្ងៃជ័យជម្នះ ៧មករា គណបក្សប្រជាជនកម្ពុជា បានជ្រោងទង់មហាសាមគ្គីជាតិដឹកនាំការស្តារ និងកសាងប្រទេសឡើងវិញ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញថ្លែងសុន្ទរកថាក្នុងមីទ្ទីញរំឭកខួបលើកទី ៧១ឆ្នាំ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា

សម្តេចតេជោ ហ៊ុន សែន អញ្ជើញចុះហត្ថលេខានៅលើសិលាចារឹក វិមាន ៧មករា

ដែលត្រូវចេញដំណើរពីចំណុចសូន្យ និងក្នុងស្ថានភាពដែលមានសន្តិភាពផង និងសង្គ្រាមផងថែមទៀត។ ទោះបីត្រូវប្រឈមមុខនឹងឧបសគ្គរាប់មឺនជំពូក និងការប៉ុនប៉ងឥតឈប់ឈរពីសំណាក់កម្លាំងអមិត្ត ដើម្បីផ្តួលរំលំគណបក្សប្រជាជនកម្ពុជាយ៉ាងណាក្តី ក៏គណបក្សប្រជាជនកម្ពុជានៅតែឈរឆ្ងាំជាមួយនឹងការគាំទ្រដ៏ធំធេងពីប្រជាជនព្រមទាំងការជួយឧបត្ថម្ភពីប្រទេសជាមិត្តជិតឆ្ងាយទាំងឡាយ រាំងស្ពាត់បានការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ស្តារ និងកសាងជាតិឡើងវិញឱ្យចេញផុតពីដំណាក់កាលដ៏សែនលំបាកបំផុត មកកាន់ដំណាក់កាលពង្រឹងពង្រីកខ្លួនបាន ហើយបន្តធ្វើដំណើរទៅមុខប្រកបដោយជោគជ័យលើមាគ៌ាសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ ជាពិសេសការបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃបង្កើតបានសន្តិភាពពេញលេញ និងការឯកភាពជាតិ ឯកភាពទឹកដីទាំងស្រុង តាមរយៈនយោបាយឈ្នះ-ឈ្នះចាប់ពីថ្ងៃទី២៩ខែធ្នូឆ្នាំ១៩៩៨មក”។សម្តេចតេជោបានថ្លែងបន្តទៀតថា៖ “ក្រោមពន្លឺនៃសន្តិភាព ប្រជាជនកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរធំៗជាវិជ្ជមានប្រកបដោយមោទនភាពបំផុតជាពិសេសនៅក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច។ ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងរយៈពេលជាង២ទសវត្សមកនេះ បានធ្វើឱ្យកម្ពុជាចេញផុតពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងខិតខំពុះពារសម្រេចនូវចក្ខុវិស័យរបស់ខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ភាពក្រីក្ររបស់ប្រជាជនត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ជីវភាពរបស់ប្រជាជនត្រូវបានលើកកម្ពស់ជាលំដាប់ សន្តិសុខ សណ្តាប់ធ្នាប់ សុខសុវត្ថិភាពសង្គមមានភាពល្អប្រសើរ លទ្ធិប្រជាធិបតេយ្យចាក់ឫសកាន់តែរឹងមាំក្នុងសង្គមខ្មែរ។ ព្រមជាមួយនោះ កិត្តិយសជាតិក៏ត្រូវបានស្តារ និងលើកស្ទួយឡើងវិញលើឆាកអន្តរជាតិ កម្ពុជាបាននិងកំពុងចូលរួមដោយស្មើភាព និងស្មើសិទ្ធិក្នុងកិច្ចការអន្តរជាតិនានាទាំងក្របខណ្ឌតំបន់ និងសកល។ បច្ចុប្បន្ន ប្រជាជនយើងកំពុងរស់នៅប្រកបដោយភាពសុខដុមរមនា មានក្តីសង្ឃឹម និងមានឱកាសសម្រាប់មនុស្សគ្រប់រូប ជាពិសេសសម្រាប់កូនៗជាយុវជនជំនាន់ក្រោយ។ សន្តិភាពដែលសម្រេចបានយ៉ាងលំបាកបំផុតដោយខ្មែរខ្លួនឯងនេះ និងសមិទ្ធផលដ៏ធំធេងនៃការស្តារកសាង និងអភិវឌ្ឍសង្គមជាតិបានបញ្ជាក់ច្បាស់នូវសច្ចធម៌មួយ គឺខ្មែរអាចធ្វើបាននូវអ្វីៗគ្រប់យ៉ាង ឱ្យតែយើងមានសាមគ្គីភាព មានភាពជឿជាក់លើបុព្វហេតុរបស់ខ្លួន ហើយរួមគ្នាដើរទៅមុខលើវិថីមួយដ៏ត្រឹមត្រូវ។ **និយាយរួមមកវាល់សមិទ្ធផលដែលគណបក្សបានសម្រេចជូនជាតិក្នុងរយៈពេល ៤៣ឆ្នាំ មកនេះ គឺអាស្រ័យដោយគណបក្សមានភាពត្រឹមត្រូវខាងនយោបាយ មានការគាំទ្រពេញទំហឹងពី ប្រជាជន មានវចនាសម្ព័ន្ធរឹងមាំ និងធនធានមនុស្សប្រកបដោយគុណធម៌ និងសមត្ថភាពមានសាមគ្គីភាពឯកភាពផ្ទៃក្នុងរឹងមាំនិងរបៀបរបបធ្វើការងារត្រឹមត្រូវ**។ ប៉ុន្តែក្នុងដំណើរទៅមុខទៀតយើងក៏មិនត្រូវភ្លេចនូវសោកនាដកម្ម ការបែកបាក់ព្រាត់ប្រាស និងការបាត់បង់ដ៏ធំធេងដែលប្រជាជាតិយើងបានជួបប្រទះពីអតីតកាលនោះឡើយ។ លើមូលដ្ឋាននេះ យើងត្រូវរួបរួមគ្នាក្នុងឆ្លុង សាមគ្គីជាតិតែមួយដើម្បីរក្សាឱ្យបាននូវសមិទ្ធផលធំៗ ដែលយើងសម្រេចបានមកដោយលំបាកបំផុតនេះ ដោយមិនត្រូវភ្លេចខ្លួន ដើរជាន់ដានប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតទោះដោយចេតនា ឬដោយអចេតនាក្តី។ ក្នុងន័យនេះ គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់គ្រប់ផ្នែក និងមន្ត្រីគណបក្សគ្រប់រូប ត្រូវបង្កើនការខិតខំបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អជាពិសេសត្រូវអនុវត្តគោលការណ៍ និងអភិក្រមនានានៃការកែទម្រង់របស់គណបក្ស ដើម្បីធ្វើឱ្យគណបក្សនៅតែរឹងមាំទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ហើយទទួលបានការស្រឡាញ់គាំទ្រពីប្រជាជនជានិច្ច”។

សម្តេចតេជោបានគូសបញ្ជាក់បន្ថែមថា៖ “ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះដែលមានគណបក្សនយោបាយចំនួន ១៧ ចូលរួម បានប្រព្រឹត្តទៅដោយជោគជ័យក្នុងបរិយាកាសនយោបាយអព្យាក្រឹតសេរី

តទៅទំព័រទី ១៦

លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ ២០២២

រាជធានី-ខេត្ត	ឃុំ	អាសនៈ	CPP		ភ្លើងទៀន		ហ៊្វុនស៊ិនប៉ិច		ខ្មែររួបរួមជាតិ		ខ្មែរស្រឡាញ់ជាតិ		សញ្ជាតិកម្ពុជា	យុវជនកម្ពុជា		កែទម្រង់កម្ពុជា	ឆន្ទៈខ្មែរ	កម្ពុជានិយម		ប្រ.ធិបតេយ្យមូលដ្ឋាន		ខ្មែរតែមួយ	សំបុកឃ្មុំ.ប្រ.តេយ្យ		ជន.ប្រ.តេយ្យកម្ពុជា	ឯកភាពជាតិខ្មែរ	ស្មើខេមរា	ខ្មែរអ.សេដ្ឋកិច្ច	សំឡេងឆ្នោត	សំឡេង
Province	Com.	Seats	សំឡេង	អាសនៈ	សំឡេង	អាសនៈ	សំឡេង	អាសនៈ	សំឡេង	អាសនៈ	សំឡេង	អាសនៈ	សំឡេង	សំឡេង	អាសនៈ	សំឡេង	សំឡេង	សំឡេង	អាសនៈ	សំឡេង	អាសនៈ	សំឡេង	សំឡេង	អាសនៈ	សំឡេង	សំឡេង	សំឡេង	សំឡេង	សរុប	មិនបានការ
បន្ទាយមានជ័យ	67	533	194,543	429	55,900	96	4,381	0	11,154	7	2,279	0	42	0		11	217	467	1	0		0	77		0	0	263	0	269,334	4,952
បាត់ដំបង	103	823	347,062	676	94,744	147	5,521	0	3,320	0	5,057	0	7	0		83	0	0		87		119	68		0	0	0	0	456,068	7,887
កំពង់ចាម	109	817	339,279	616	125,875	196	4,836	0	1,780	0	6,201	3	2,469	1,155	1	506	145	357		223		512	704	1	0	0	0	0	484,042	10,316
កំពង់ឆ្នាំង	71	427	202,957	337	66,991	90	6,323	0	3,387	0	1,021	0	683	851		0	0	826		1,036		0	146		0	19	0	0	284,240	6,633
កំពង់ស្ពឺ	88	616	384,954	526	90,002	90	5,946	0	6,230	0	3,436	0	305	70		151	201	0		410		179	161		0	347	147	188	492,727	12,018
កំពង់ធំ	81	585	205,882	406	94,323	165	16,226	12	3,758	0	4,296	0	2,131	241		220	221	191		1,068	2	83	0		0	0	0	72	328,712	6,478
កំពត	93	561	232,479	440	75,999	117	5,279	2	807	0	0	0	0	2,477	1	0	0	0		588	1	0	0		0	0	0	0	317,629	9,059
កណ្ដាល	127	915	481,744	727	154,371	187	5,008	1	1,152	0	2,482	0	2,081	327		550	1,306	38		96		42	264		0	0	0	0	649,461	13,671
កោះកុង	29	167	44,992	145	10,356	21	64	0	168	0	125	0	0	848	1	0	0	0		0		0	0		0	0	0	0	56,553	1,160
ក្រចេះ	48	300	120,550	244	35,216	55	5,505	1	3,837	0	196	0	0	498		0	0	0		0		0	0		190	0	0	0	165,992	3,433
មណ្ឌលគិរី	21	107	29,676	104	4,434	3	281	0	28	0	0	0	93	121		0	0	0		0		0	0		1,414	0	0	0	36,047	1,011
រាជធានីភ្នំពេញ	105	899	536,625	743	151,262	154	3,395	1	2,805	1	197	0	70	1,417		0	848	103		458		0	170		0	0	0	0	697,350	16,035
ព្រះវិហារ	51	333	84,791	260	25,130	70	1,763	0	1,393	1	693	0	555	76		74	0	0		612	2	0	0		0	0	0	0	115,087	3,039
ព្រៃវែង	116	892	398,045	684	140,728	206	3,783	0	4,351	0	2,743	2	2,961	799		0	916	2,556		0		264	703		0	0	0	0	557,849	12,901
ពោធិ៍សាត់	49	341	195,656	311	32,143	30	605	0	679	0	94	0	213	0		92	0	0		0		0	0		0	0	0	0	229,482	3,802
រតនគិរី	50	260	69,838	236	11,735	22	160	0	1,459	1	0	0	0	0		0	0	0		605	1	0	0		30	0	0	0	83,827	2,741
សៀមរាប	100	668	306,668	514	115,589	153	6,938	0	6,941	1	2,287	0	162	1,037		633	653	171		894		0	35		0	0	36	0	442,044	7,844
ព្រះសីហនុ	29	177	86,308	161	17,400	16	1,857	0	427	0	24	0	13	1,084		35	0	70		0		32	0		0	498	0	0	107,748	2,116
ស្ទឹងត្រែង	34	176	55,898	155	12,009	19	2,663	2	440	0	0	0	130	544		0	0	0		0		0	0		0	0	0	0	71,684	1,687
ស្វាយរៀង	80	518	245,164	418	75,528	100	3,480	0	1,386	0	0	0	589	202		0	0	77		427		0	132		0	0	0	0	326,985	7,397
តាកែវ	100	736	406,958	597	118,061	139	2,331	0	3,028	0	223	0	271	306		4,538	178	0		193		317	0		0	262	0	34	536,700	11,982
កែប	5	31	19,284	29	2,893	2	442	0	105	0	0	0	0	0		0	0	0		0		0	0		0	0	0	0	22,724	542
ប៉ៃលិន	8	52	25,456	47	5,095	5	0	0	544	0	0	0	7	0		0	0	0		20		0	0		0	0	0	0	31,122	476
ឧត្ដរមានជ័យ	24	152	87,069	139	16,353	13	178	0	2,615	0	1,647	0	65	0		0	0	0		0		0	0		0	0	0	0	107,927	2,382
ត្បូងឃ្មុំ	64	536	276,895	432	78,419	102	4,833	0	2,074	2	258	0	293	1,788		663	339	0		90		51	0		0	0	0	0	365,703	7,828
សរុប	1,652	11622	5,378,773	9,376	1,610,556	2,198	91,798	19	63,868	13	33,259	5	13,140	13,841	3	7,556	5,024	4,856	1	6,807	6	1,599	2,460	1	1,634	1,126	446	294	7,237,037	157,390
28-Jun-22		100%	74.32%	80.67%	22.25%	18.91%	1.27%	0.16%	0.88%	0.11%	0.46%	0.04%	0.18%	0.19%	0.03%	0.10%	0.07%	0.07%	0.01%	0.09%	0.05%	0.02%	0.03%	0.01%	0.02%	0.02%	0.01%	0.00%	100%	2.17%

*CPP ទទួលបានមេឃុំ ចៅសង្កាត់ ចំនួន ១.៦៤៨ (ស្ត្រី ចំនួន ១៧៣ និងយុវជន ចំនួន ៣៧នាក់) ជំទប់-ចៅសង្កាត់រងទី ១ ចំនួន ១.៦១៨ និងជំទប់-ចៅសង្កាត់រងទី ២ ចំនួន ២៦១

*គណបក្សភ្លើងទៀន ទទួលបានមេឃុំ ចំនួន ៤ ជំទប់-ចៅសង្កាត់រងទី ១ ចំនួន ២៥ និងជំទប់-ចៅសង្កាត់រងទី ២ ចំនួន ១.៣៦០

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃអាទិត្យ ១២រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័កព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០២២

សេចក្តីថ្លែងការណ៍
របស់គណបក្សប្រជាជនកម្ពុជា

សូមក្រាបថ្វាយបង្គំ ព្រះថេរា នុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
បងប្អូនជនរួមជាតិជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត!

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០២២ បានប្រព្រឹត្តទៅស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាស អព្យាក្រឹត សន្តិសុខ របៀបរៀបរយ គ្មានអំពើហិង្សា និងការគំរាមកំហែង។ គ្រប់គណបក្សដែលបានចូលរួមបោះឆ្នោត មានឱកាសពេញលេញក្នុងការធ្វើសកម្មភាពស្របតាមបទបញ្ញត្តិនៃច្បាប់ ដើម្បីស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋខ្មែរជាង៨០%នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានអនុវត្តយ៉ាងពេញលេញនូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួន ដោយបានអញ្ជើញទៅបោះឆ្នោតយ៉ាងច្រើនកុះករប្រកបដោយភាពថ្លៃថ្នូរ សប្បាយរីករាយ និងតាមឆន្ទៈរបស់ខ្លួន ដើម្បីជ្រើសតាំងតំណាងដែលខ្លួនពេញចិត្តឱ្យបន្តដឹកនាំឃុំ សង្កាត់ ពីឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៧ បន្តទៀត។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បានឆ្លុះបញ្ចាំងអំពីភាពចាស់ទុំនៃដំណើរការប្រជាធិបតេយ្យជាទៀងទាត់នៅកម្ពុជា ជាពិសេសនៅថ្នាក់មូលដ្ឋានក្រោមពន្លឺនៃសន្តិភាព។ ជោគជ័យនេះក៏ទទួលបាន ក្នុងខណៈដែលព្រះរាជាណាចក្រកម្ពុជាកំពុងងើបឡើងវិញពីវិបត្តិដំងឺកូវីដ-១៩ និងសម្រេចបានសមិទ្ធផលថ្មីៗបន្តទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមជាមួយនេះ កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាក៏កាន់តែត្រូវបានលើកកម្ពស់ឡើងនៅលើឆាកអន្តរជាតិ ស្របពេលដែលកម្ពុជាកំពុងទទួលតួនាទីជាប្រធានអាស៊ាន និងការត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ នៅឆ្នាំ២០២៣ខាងមុខ។

គណបក្សប្រជាជនកម្ពុជា សូមប្រកាសជាឧឡារិក ទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាស នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២នេះ។ លទ្ធផលនៃការបោះឆ្នោតនេះ បានកើតចេញពីទឹកចិត្ត ឆន្ទៈ និងវិចារណញ្ញាណរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោតពិតប្រាកដ ដែលមានសេចក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំចំពោះការរីកចម្រើនរបស់ភូមិ ឃុំសង្កាត់និងការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួនបន្តទៀតហើយបានបដិសេធនូវការកុហកបោកប្រាស ញុះញង់មួលបង្កាច់ការពិតរបស់ពួកប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអគតិមួយចំនួនដែលតែងតែរារាំងដំណើរអភិវឌ្ឍន៍កម្ពុជា។ ការសម្រេចចិត្តប្រកបដោយសុភវិនិច្ឆ័យរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោតនេះ បានឆ្លុះបញ្ចាំងនូវការផ្តល់យុត្តិធម៌ចំពោះកិច្ចខិតខំប្រឹងប្រែងប្រកបដោយជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តកម្មវិធីនយោបាយរបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការគាំទ្រយ៉ាងទូលំទូលាយចំពោះគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧ របស់គណបក្សប្រជាជនកម្ពុជា។

គណបក្សប្រជាជនកម្ពុជា សូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះបងប្អូនជនរួមជាតិនៅគ្រប់ឃុំ សង្កាត់ ទូទាំងប្រទេស ដែលបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាយ៉ាងច្រើនលើសលប់ ធ្វើឱ្យគណបក្សទទួលបានជោគជ័យដ៏ត្រចះត្រចង់។ តាមរយៈជ័យជម្នះនេះ បានបង្ហាញថា ប្រជាជនបានបោះឆ្នោត

ជ្រើសរើសយកសន្តិភាព និងការអភិវឌ្ឍដែលមានតម្លៃលើសអ្វីៗទាំងអស់ ព្រមជាមួយនោះបានពង្រីងមូលដ្ឋានសម្រាប់គណបក្សប្រជាជនកម្ពុជា ឈានទៅទទួលបានជ័យជម្នះដ៏ត្រចះត្រចង់ជាថ្មីទៀត ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នា ឆ្នាំ២០២៣ ខាងមុខ។

គណបក្សប្រជាជនកម្ពុជា សូមគោរព និងកោតសរសើរ ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ដែលបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយភាពឯករាជ្យ អព្យាក្រឹតឥតលម្អៀង តម្លាភាព និងយុត្តិធម៌ ក្នុងជំហរទទួលខុសត្រូវខ្ពស់ចំពោះឧត្តមប្រយោជន៍ជាតិ និងប្រជាជន ធ្វើឱ្យដំណើរការរៀបចំការបោះឆ្នោតនៅគ្រប់ដំណាក់កាលបានប្រព្រឹត្តទៅយ៉ាងល្អប្រសើរស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។

គណបក្សប្រជាជនកម្ពុជា សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាល អាជ្ញាធរដែនដី និងកងកម្លាំងមានសមត្ថកិច្ចនៅគ្រប់លំដាប់ថ្នាក់ ដែលបានយកអស់លទ្ធភាពជួយគាំទ្រយ៉ាងសកម្មដល់ដំណើរការរៀបចំការបោះឆ្នោត ជាពិសេស ការការពារសន្តិសុខ សណ្តាប់ធ្នាប់ទូទៅសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោត ធ្វើឱ្យដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅយ៉ាងរលូនតាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់។

គណបក្សប្រជាជនកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមអ្នកអង្កេតការណ៍ជាតិមកពីគ្រប់គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលនានា និងមជ្ឈដ្ឋានផ្សេងៗទៀត ព្រមទាំងអ្នកសង្កេត-ការណ៍អន្តរជាតិ ដែលបានតាមដានពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ចំពោះដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោត ហើយបានធ្វើការវាយតម្លៃប្រកបដោយភាពសត្យានុម័តចំពោះការបោះឆ្នោតនេះ ថាជាការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះបណ្តាប្រទេសជាមិត្ត និងសហគមន៍អន្តរជាតិ ដែលតែងជួយគាំទ្រដល់ដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ហើយបានតាមពិនិត្យមើលដំណើរការបោះឆ្នោតនេះ និងបានវាយតម្លៃប្រកបដោយភាពវិជ្ជមានចំពោះការបោះឆ្នោត។

គណបក្សប្រជាជនកម្ពុជា សូមប្តេជ្ញាចំពោះមុខប្រជាជនថា គណបក្សនឹងអនុវត្តគោលនយោបាយរបស់ខ្លួនឱ្យបានជោគជ័យ ដើម្បីរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមឱ្យបានរឹងមាំ លើកកម្ពស់ការផ្តល់សេវាសាធារណៈ បង្កើនកិច្ចគាំពារសង្គមជួយជនក្រីក្រ និងងាយរងគ្រោះ និងអភិវឌ្ឍឃុំ សង្កាត់លើគ្រប់វិស័យឱ្យកាន់តែរីកចម្រើនឡើង ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នា និងផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនគ្រប់ៗរូបនៅគ្រប់មូលដ្ឋាន។

គណបក្សប្រជាជនកម្ពុជា សូមអំពាវនាវដល់បងប្អូនជនរួមជាតិនៅគ្រប់ទិសទី ទោះបីបានបោះឆ្នោតគាំទ្រគណបក្សណាក្តី ឬមិនបានទៅបោះឆ្នោតក្តី សូមបន្តរួបរួមសាមគ្គីគ្នាជាធ្លុងមួយក្រោមដំបូលរដ្ឋធម្មនុញ្ញ និងម្លប់បារមីន**អៃខ្ពព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្តារៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង និងរួមសាមគ្គីគ្នាជុំវិញរាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ដើម្បីបន្តថែរក្សាសន្តិភាព ការពាររាល់សមិទ្ធផលសង្គមជាតិ និងអភិវឌ្ឍមាតុភូមិជាទីស្នេហានៃយើងឆ្ពោះទៅរកអនាគតដ៏រុងរឿង។

សូមប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធពរជូនបងប្អូនជនរួមជាតិ ទាំងនៅក្នុងប្រទេសទាំងនៅក្រៅប្រទេស សូមបានប្រកបពុទ្ធពរ និងពរទាំង ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

គណបក្សប្រជាជនកម្ពុជា

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ដំណើរការដោយរលូន និងប្រកបដោយជោគជ័យ

ការបើកយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២

ក្បួនយុទ្ធនាការបញ្ចប់ឃោសនាវគសម្លេងឆ្នោតនៅរាជធានីភ្នំពេញ ដោយមានសមាជិក និងប្រជាពលរដ្ឋចូលរួមជាង៣ម៉ឺននាក់

ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ឆ្នាំ២០២២បានបញ្ចប់ដោយរលូននិងជោគជ័យខណៈដែលការរៀបចំការបោះឆ្នោតនេះ កម្ពុជាម្ចាស់ការដោយខ្លួនឯង ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ការបោះឆ្នោតទទួលបាននូវការវាយតម្លៃខ្ពស់ពីអ្នកសង្កេតការណ៍ជាតិ អ្នកសង្កេតការណ៍អន្តរជាតិ ស្មៀវពិសេសរបស់កម្ពុជា ភ្នាក់ងារសង្កេតការណ៍របស់គណបក្ស ដោយចាត់ទុកថា បានប្រព្រឹត្តទៅស្របតាមការបោះឆ្នោតជាសកលដោយការបោះឆ្នោតសម្ងាត់ និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នីតិរដ្ឋ និងសិទ្ធិមនុស្សសកលដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាជាភាគី។

ដំណើរការបោះឆ្នោត៖

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ បានប្រព្រឹត្តទៅនៅព្រឹកថ្ងៃអាទិត្យ ទី៥ ខែមិថុនា ដោយចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៣ រសៀល ដោយមានគណបក្សនយោបាយចំនួន១៧ បានចូលរួមប្រកួតប្រជែង ដោយបានដាក់បេក្ខជនក្រុមប្រឹក្សាឃុំសង្កាត់សរុប៨៦.០៩២នាក់(ស្ត្រី២៧.៨១៣នាក់)។

ដោយឡែក ឃុំ សង្កាត់ ក្នុងអាណត្តិទី៥ នេះ មានចំនួន ១.៦៥២ ហើយចំនួនក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលនឹងត្រូវជ្រើសរើសមកបម្រើការងារក្នុង ឃុំ សង្កាត់ ទាំងអស់នេះ មានចំនួន ១១.៦២២រូប។

យោងតាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានឱ្យដឹងថា ដំណើរការបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥នេះ មានការិយាល័យបោះឆ្នោតសរុបចំនួន ២៣.៦០២ ការិយាល័យ ។ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន៩.២០៥.៦៨១នាក់ ស្មើនឹង ៨៧,៩៤ ភាគរយនៃប្រជាជនកម្ពុជាទាំងអស់ ក្នុងនោះមានស្រីចំនួន ៤.៩០៤.៨៣២នាក់។ សន្លឹកឆ្នោតដែលត្រូវប្រើប្រាស់មានចំនួន ១១.៦១១.៤០០សន្លឹក និងសន្លឹកឆ្នោតបម្រុងជាង ១,២ លានសន្លឹក (១.២៣៩.០០០សន្លឹក) ។ ទឹកខ្មៅលុបលាងមិនជ្រះដែលបញ្ជាទិញពីក្រុមហ៊ុននៃប្រទេសឥណ្ឌាមានចំនួន ៥២ ០០០ដប។

គណបក្សនយោបាយទាំង១៧ ដែលចូលរួមក្នុងការដាក់បេក្ខជនក្រុមប្រឹក្សា ឃុំ សង្កាត់ មាន៖ **១.** គណបក្សប្រជាជនកម្ពុជា ដាក់បេក្ខជនឈរឈ្មោះបានចំនួន ១.៦៥២/១.៦៥២ ឃុំ សង្កាត់, **២.** គណបក្សហ្វ៊ុនស៊ិនប៉ិច ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៦៨០/១.៦៥២ ឃុំ សង្កាត់ , **៣.** គណបក្សខ្មែររួបរួមជាតិ ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៥៩៦/១.៦៥២ ឃុំ សង្កាត់, **៤.** គណបក្សខ្មែរស្រឡាញ់ជាតិ ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៣១៥/១.៦៥២ ឃុំ សង្កាត់, **៦.** គណបក្សសញ្ជាតិកម្ពុជា ដាក់បេក្ខជនឈរឈ្មោះបានចំនួន ២៤៥/១.៦៥២ ឃុំ សង្កាត់, **៧.** គណបក្សយុវជនកម្ពុជា ដាក់បេក្ខជនឈរឈ្មោះបានចំនួន ១១៤/១.៦៥២ ឃុំ សង្កាត់, **៨.** គណបក្សកែទម្រង់កម្ពុជា ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៥៩/១.៦៥២ ឃុំ សង្កាត់, **៩.** គណបក្សឆន្ទៈខ្មែរ ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៥៨/១.៦៥២ ឃុំ សង្កាត់, **១០.** គណបក្សកម្ពុជានិយម ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៣៨/១.៦៥២ ឃុំ សង្កាត់, **១១.** គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៣២/១.៦៥២ ឃុំ សង្កាត់,**១២.** គណបក្សខ្មែរតែមួយ ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៣០/១.៦៥២ ឃុំ សង្កាត់,**១៣.** គណបក្សសំបុកឃ្មុំ សង្គមប្រជាធិបតេយ្យ ដាក់បេក្ខជនឈរឈ្មោះបានចំនួន ២៣/១.៦៥២ ឃុំ សង្កាត់, **១៤.** គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា ដាក់បេក្ខជនឈរឈ្មោះបានចំនួន ១៩/១.៦៥២ ឃុំ សង្កាត់, **១៥.** គណបក្សឯកភាពជាតិខ្មែរ ដាក់បេក្ខជនឈរឈ្មោះបានចំនួន ១៤/១.៦៥២ ឃុំ សង្កាត់,**១៦.** គណបក្សរស្មីខេមរា ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៦/១.៦៥២ ឃុំ សង្កាត់និង**១៧.** គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ដាក់បេក្ខជនឈរឈ្មោះបានចំនួន ៤/១.៦៥២ ឃុំ សង្កាត់។

ដើម្បីធានាបាននូវតម្លាភាព និងយុត្តិធម៌នៃដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ការបោះឆ្នោតបានប្រព្រឹត្តទៅដោយមានវត្តមានអ្នកសង្កេតការណ៍ជាតិចំនួន ៧២ ស្ថាប័ន អ្នកសង្កេតការណ៍ជាតិសរុប ៧៤ ៩០៤ នាក់ អ្នកសង្កេតការណ៍អន្តរជាតិមានចំនួន ២០ ស្ថាប័ន និងមានអ្នកសង្កេតការណ៍ចំនួន

សម្តេចតេជោ ហ៊ុន សែន *និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញបោះឆ្នោតនៅសាលាគរុកោសល្យ និង វិក្រឹត្យការ ក្រុងតាខ្មៅ*

សម្តេចក្រឹ ហេង សំរិន *អញ្ជើញបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំកក់ ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ*

១១០នាក់ ភ្ញៀវពិសេស មានចំនួន ២៣ នាក់ មកពីស្ថានទូតជប៉ុន ស្ថានទូតអូស្ត្រាលី និងស្ថានទូតរុស្ស៊ី ក៏បានសុំចូលរួមពិនិត្យមើលការបោះឆ្នោត ដោយមិនមែនក្នុងនាមជាអ្នកសង្កេតការណ៍នោះឡើយ។ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិដែលចូលរួមសង្កេតការណ៍ ក្នុងការបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ មានដូចជា៖ តំណាងអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិ (Centralist Democrat International CDI-IDC)។ តំណាងអង្គការអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិប្រចាំអាស៊ីប៉ាស៊ីហ្វិក (Centralist Asia-Pacific Democrat International-CAPDI)។ តំណាងអង្គការសន្និសិទអន្តរជាតិនៃបណ្តាគណបក្សនយោបាយនៅអាស៊ី (International Conference of the Asian Political Parties - ICAPP)។ តំណាងវេទិកាស្ថាប័នស្រាវជ្រាវសកល 2022 (Think Tank 2022 Global Forum)។ តំណាងសហគមន៍អន្តរសភាអាស៊ាន (ASEAN Inter-Parliament Association - AIPA)។ តំណាងសភាអន្តរជាតិដើម្បីសន្តិភាព និងភាពអត់ឱន (International Parliament Tolerance and Peace - IPTP)។ តំណាងក្រុមអ្នកសង្កេតការណ៍ឯករាជ្យ (Independence Observer)។ តំណាងសហគមន៍ខ្មែរនៅក្រៅប្រទេស ។ សហគមន៍ខ្មែរជីលីងតុន (Khmer Culture Association of Wellington Inc. New Zealand) និងសហគមន៍ខ្មែរនៅកូរ៉ៃ។ ចំណែក អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលចូលរួមយកព័ត៌មាននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ មានចំនួន ៨១៤នាក់។ ក្នុងនោះអ្នកសារព័ត៌មានជាតិចំនួន ៧៧៥ នាក់ និងអ្នកសារព័ត៌មានអន្តរជាតិចំនួន ៣៩ នាក់។

ថ្ងៃទី៥ ខែមិថុនា គឺជាថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិ៥ ។ ការបោះឆ្នោតបានចាប់ផ្តើមពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៣រសៀល។ ទោះជាមានបញ្ហាអាកាសធាតុមិនល្អនៅកន្លែងខ្លះក៏ដោយ ក៏ការបោះឆ្នោតបានដំណើរការដោយរលូន តាំងពីពេលចាប់ផ្តើម រហូតដល់ពេលបិទការិយាល័យបោះឆ្នោត។

គ.ជ.ប បានបញ្ជាក់នៅពេលបិទបញ្ចប់ការិយាល័យបោះឆ្នោតទាំងអស់ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៥ បានដំណើរការប្រព្រឹត្តទៅដោយជោគជ័យ ក្រោមបរិយាកាសស្ងប់ស្ងាត់ សុខសន្តិភាព និងគ្មានអំពើហិង្សា។

ដំណើរការបោះឆ្នោតនេះ ក៏បានទទួលនូវកោតសរសើរ និងការវាយតម្លៃខ្ពស់ពីក្រុមអ្នកសង្កេតការណ៍អន្តរជាតិផងដែរ ។ ក្រុមអ្នកសង្កេតការណ៍អន្តរជាតិបានចេញសេចក្តីថ្លែងការណ៍រួមមួយ ដោយបញ្ជាក់ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៥ របស់កម្ពុជា នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ បានប្រព្រឹត្តទៅស្របតាមការបោះឆ្នោតជាសកល ដោយការបោះឆ្នោតសម្ងាត់ និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នីតិរដ្ឋ និងសិទ្ធិមនុស្សសកល ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាជាភាគី។ នៅថ្ងៃបោះឆ្នោត អ្នកសង្កេតការណ៍អន្តរជាតិបានចុះទៅពិនិត្យការិយាល័យបោះឆ្នោតភ្លាមៗ មុននឹងបើកដើម្បីបានមើលការត្រៀមរៀបចំរបស់បុគ្គលិក គ.ជ.ប ដើម្បីធានាឱ្យដំណើរការបោះឆ្នោតមានភាពត្រឹមត្រូវ។ ជាលទ្ធផល អ្នកសង្កេតការណ៍បានកត់សម្គាល់ថា វិជ្ជាជីវៈ និងភាពស្មោះត្រង់របស់បុគ្គលិក គ.ជ.ប មានស្តង់ដារខ្ពស់។ ជាងនេះទៅទៀត ដើម្បីទទួលបានការយល់ដឹងច្រើនបំផុត អំពីដំណើរការបោះឆ្នោត គណៈប្រតិភូក៏បានអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួន នៅតាមការិយាល័យបោះឆ្នោតមួយចំនួនផងដែរ។ ដូចនេះគណៈប្រតិភូ បានសង្កេតឃើញថា អាជ្ញាធរកម្ពុជាគ្រប់លំដាប់ថ្នាក់បានបង្កើតនូវលក្ខខណ្ឌអំណោយផល សម្រាប់គ្រប់គណបក្សនយោបាយទាំងអស់ក្នុងការចូលរួម ដោយសេរី និងយុត្តិធម៌ ក្នុងដំណើរការបោះឆ្នោតទូទាំងប្រទេស។ សេចក្តីថ្លែងការណ៍ដដែល បានកត់សម្គាល់ថា អត្រាអ្នកទៅបោះឆ្នោតមានលើសពី ៧៧,៩ ភាគរយនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលបង្ហាញពីការចូលរួមយ៉ាងសកម្មរបស់ប្រជាជនកម្ពុជា ក្នុងដំណើរការនយោបាយ និងលទ្ធិប្រជាធិបតេយ្យ ជាពិសេស ក្នុងការលើកកម្ពស់តម្លៃសិទ្ធិមនុស្ស និងគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។ ទោះបីជាមានការតវ៉ាខ្លះ ដែល គ.ជ.ប បានទទួលក៏ដោយ ក៏គណៈប្រតិភូមិនឃើញមានឧប្បត្តិហេតុណាមួយ ដែលអាចប៉ះពាល់ដល់ដំណើរការ ឬ លទ្ធផលនៃការបោះឆ្នោត ឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះឡើយ ។ សេចក្តីថ្លែងការណ៍រួម បានវាយតម្លៃថា «គណៈប្រតិភូជឿជាក់យ៉ាងមុតមាំថា ការបោះឆ្នោតបានប្រព្រឹត្តទៅដោយសន្តិវិធី ដោយសេរី យុត្តិធម៌ តម្លាភាព និងបរិយាប័ន្ន។ គណៈប្រតិភូបានសង្កេតឃើញថា ការបោះឆ្នោតឃុំសង្កាត់ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ប្រព្រឹត្តទៅស្របតាមការបោះឆ្នោតជាសកល ដោយការបោះឆ្នោតសម្ងាត់ និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នីតិរដ្ឋ និងសិទ្ធិមនុស្សសកល ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាជាភាគី» ។ អ្នកសង្កេតការណ៍អន្តរជាតិក៏បានអំពាវនាវដល់សហគមន៍អន្តរជាតិ គ្រប់គណបក្សនយោបាយនិងអ្នកពាក់ព័ន្ធទាំងអស់សហការក្នុងន័យស្ថាបនាជាមួយប្រជាជនកម្ពុជា និងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាបាននូវភាពបន្តនៃសង្គមកម្ពុជា ប្រកបដោយសន្តិភាព សុខដុមរមនា និង

សម្តេចក្រឡាហោម ស ខេង *អញ្ជើញទៅបោះឆ្នោតរួចហើយ នៅការិយាល័យលេខ៥០៣ ក្នុងវិទ្យាល័យសោហី សង្កាត់ស្វាយប៉ោ ខេត្តបាត់ដំបង*

សម្តេចកិត្តិ សាយ ឈុំ *និងលោកជំទាវអញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅវិទ្យាល័យវត្តកោះ*

សម្តេចពិជ័យសេនា ទៀ បាញ់ *អញ្ជើញទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥*

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន *អញ្ជើញទៅចូលរួមបោះឆ្នោតនៅសាលាសាលាបឋមសិក្សាព្រះសីហនុ ខេត្តស្វាយរៀង*

រួមចំណែកបន្ថែមទៀតដល់សង្គមជាតិ។ ការអភិវឌ្ឍ និងវិបុលភាពរបស់ប្រទេសដែលនឹងជួយធានាសន្តិភាព និងស្ថិរភាពក្នុងតំបន់និងក្រៅតំបន់។

សូមបញ្ជាក់ថា ប្រជាពលរដ្ឋដែលបានអញ្ជើញទៅបោះឆ្នោត មានចំនួន ៧.៣៨២.៤៤៩ នាក់ ស្មើនឹង ៨០,១៩ភាគរយ នៃចំនួនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត សរុប ៩.២០៥.៦៨១នាក់ ។ ចំណែកឯសន្លឹកឆ្នោតបានការ មានចំនួន ៧.២៣៦.២៤៤សន្លឹក។ សន្លឹកឆ្នោតមិនបានការ មានចំនួន ១៤៦.២០៥ សន្លឹក ស្មើនឹង ១,៩ ភាគរយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ។ គណបក្សនយោបាយចំនួនបួន បាននាំមុខគេ ដោយទទួលបាននូវការគាំទ្រពីប្រជាពលរដ្ឋក្នុងការបោះឆ្នោតនេះ គឺ **១.** គណបក្សប្រជាជនកម្ពុជា ទទួលបានសំឡេង ៥.៣៣៧.៧៥៤ សំឡេង គិតជាភាគរយស្មើ ៧៤,៣២ភាគរយ។ **២.** គណបក្សភ្លើងទៀន ទទួលបាន ១.៦១០.៤៣៤សំឡេង ស្មើ ២២,២៦ភាគរយ ។ **៣.** គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ៩១.៧៩៣ សំឡេង ស្មើ ១,២៧ ភាគរយ និងគណបក្សខ្មែររួបរួមជាតិ ទទួលបាន ៦៣.៩៤៧សំឡេងស្មើ ០,៨៨ ភាគរយ។ ចំណែកគណបក្សខ្មែរស្រឡាញ់ជាតិ ៣៣.៣០៥ សំឡេង ស្មើ ០,៥២ ភាគរយ។

លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ បានឆ្លុះបញ្ចាំងឱ្យឃើញនូវកម្លាំងគាំទ្រគណបក្សប្រជាជនកម្ពុជាមានការកើនឡើងពីមួយអាណត្តិទៅមួយអាណត្តិ និងបង្ហាញផងដែរពីភាពចាស់ទុំរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន និងដំណើរការកសាងអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យក្រោមពន្លឺនៃសន្តិភាព៕

ប្រជាពលរដ្ឋទូទាំងប្រទេស អញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ នៅតាមមូលដ្ឋាននានា

សន្និសីទសារព័ត៌មាន ដោយអ្នកសង្កេតការណ៍អន្តរជាតិ

សម្តេចតេជោ ហ៊ុន សែន៖ យើងត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីបើកចំហ និង គាំទ្រប្រព័ន្ធពាណិជ្ជកម្ម ពហុភាគី និងពង្រឹងពហុភាគីនិយម ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព

សម្តេចតេជោ ហ៊ុន សែន អញ្ជើញថ្លែងសុន្ទរកថា ក្នុងព្រឹត្តិការណ៍ «BRICS Plus» ដែលរៀបចំនៅក្រុងប៉េកាំង តាមប្រព័ន្ធអនឡាញ

តបតាមការអញ្ជើញរបស់ ឯកឧត្តម **ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រមានិតចិន, នៅយប់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចសន្ទនាជាន់ខ្ពស់នៃថ្នាក់ដឹកនាំប្រទេស «ប្រ៊ីកបូក (BRICS Plus)» ស្តីពីការអភិវឌ្ឍសកល ក្រោមមូលបទ **«លើកកម្ពស់ភាពជាដៃគូអភិវឌ្ឍន៍សកល សម្រាប់យុគសម័យថ្មីដើម្បីរួមគ្នាអនុវត្តរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព»** តាមប្រព័ន្ធវីឌីអូ។

តាមរយៈសុន្ទរកថាគន្លឹះថ្លែងក្នុងកិច្ចសន្ទនាដ៏មានសារៈសំខាន់នេះ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា បានគូសបញ្ជាក់ថា បច្ចុប្បន្ននេះ, តំបន់ និងសកលលោក បាននិងកំពុងបន្តប្រឈមកាន់តែស្មុគស្មាញ ហើយកាន់តែស្មុគស្មាញ និងមិនអាចប៉ាន់ប្រមាណបានចំពោះការអភិវឌ្ឍ រួមមាន ការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ, សង្គ្រាមយោធា,ពាណិជ្ជកម្មនិងបច្ចេកវិទ្យា,ការប្រែប្រួលអាកាសធាតុ, ការរីតបន្តឹងនូវគោលនយោបាយរូបិយវត្ថុ ។ល។ កត្តាទាំងនេះបាននិងកំពុងបង្កឱ្យមានការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ចសកលលោក និងបន្ទុចបង្អាក់ចរន្តសកលភាវូបនីយកម្ម ដែលធ្វើឱ្យខ្សែច្រវាក់តម្លៃសកល និងផលិតភាពសកលមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ **សម្តេចតេជោ ហ៊ុន សែន** បានបន្តថា ស្ថិតក្នុងបរិការណ៍ដែលការរីករាលដាលនៃជំងឺកូវីដ-១៩ បានស្រាកស្រាន្ត និងការខិតខំស្តារសេដ្ឋកិច្ចសកលលោក ជាអាទិភាពចំពោះមុខ,ប្រ៊ីក(BRICS)ដែលជាសេដ្ឋកិច្ចកំពុងលូតលាស់ខ្លាំងប្រកបដោយសក្តានុពល មានតួនាទីកាន់តែសំខាន់មិនអាចខ្វះបានក្នុងការពង្រីក និងពង្រឹងចលនានៃសកម្មភាពសេដ្ឋកិច្ចសកលលោក ឱ្យត្រលប់ទៅរកកំណើនសក្តានុពលដើម្បីពន្លឿនការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ក្នុងន័យនេះ, កិច្ចសហប្រតិបត្តិការ ប្រ៊ីកបូក (BRICS Plus) ជាកាលានុវត្តភាពមួយដ៏សំខាន់សម្រាប់ពង្រឹងភាពជាដៃជាមួយបណ្តាប្រទេសផ្សេងៗ ក្នុងការបង្កើតវេទិកាសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការ ជាក់ស្តែងក្នុងវិស័យអាទិភាពសំខាន់ៗ ដើម្បីបង្កើតឱកាសការងារ, កាត់បន្ថយភាពក្រីក្រ ព្រមទាំងការធានាសន្តិសុខស្បៀង និង ថាមពលជាដើម ក្នុងការសម្រេចឱ្យបាននូវរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងបរិបទនេះ, យើងត្រូវតែប្រកាន់ខ្ជាប់នូវស្មារតីបើកចំហ និង គាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគី និងពង្រឹងពហុភាគីនិយម ជាពិសេសលើកកម្ពស់ការបើកចំហសម្រាប់ពាណិជ្ជកម្មអន្តរជាតិ និងកាត់បន្ថយរបាំងពាណិជ្ជកម្មនានាជាពិសេសលើទំនិញយុទ្ធសាស្ត្រ ដូចជាស្បៀងអាហារ, ថ្នាំពេទ្យ និងថាមពល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងពង្រឹងភាពធន់នៃខ្សែច្រវាក់តម្លៃតំបន់ និងសកល ។ ការពង្រឹង និង ពង្រីកកិច្ចសហការក្នុងវិស័យសង្គម-សេដ្ឋកិច្ចថ្មីៗ ក៏ជាកិច្ចការអាទិភាពផងដែរ។ យើងគួរផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការ បង្កើនកិច្ចសហការក្នុងការពង្រឹងសមត្ថភាព និងពន្លឿនការធ្វើបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ដែលជាប្រភពកំណើនថ្មី ជាពិសេស ជួយប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ទាប ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ។ បន្ថែមលើនេះ, ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ក៏ជាផ្នែកមួយមិនអាចខ្វះបានសម្រាប់ទ្រទ្រង់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព តាមរយៈការគាំទ្រការពង្រីកកិច្ចសហប្រតិបត្តិការ លើការកសាងហេដ្ឋារចនាសម្ព័ន្ធបៃតង, ការជំរុញការធ្វើអន្តរកាលថាមពល និងការប្រើប្រាស់បច្ចេក-វិទ្យាបៃតង ជាដើម។

ក្នុងនាមជាប្រធានអាស៊ានសម្រាប់ឆ្នាំ ២០២២, **សម្តេចតេជោ ហ៊ុន សែន** បានធ្វើការប្តេជ្ញាថា កម្ពុជានឹងខិតខំប្រឹងប្រែងដើរតួនាទីយ៉ាងសកម្មបន្ថែមទៀត ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ានជាមួយដៃគូ ក្នុងគោលដៅជំរុញការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ប្រកបដោយបរិយាប័ន្ន, ចីរភាព និងភាពធន់ ដើម្បីឆ្ពោះទៅរកការសម្រេចបាននូវរបៀបវារៈ ឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ជាមួយគ្នានេះ ឯកឧត្តម **ស៊ី ជីនពីង** ប្រធានាធិបតីចិន បានគូសបញ្ជាក់ថា ក្នុងឋានៈជាទីផ្សារធើបឡើងថ្មីដ៏សំខាន់ និងប្រទេសកំពុងអភិវឌ្ឍន៍ដ៏ធំប្រទេស BRICS ត្រូវតែហ៊ានទទួលខុសត្រូវ ហ៊ានធ្វើការជាក់ស្តែងដើម្បីបំពេញបន្ថែមកម្លាំងវិជ្ជមាន ដែលប្រកបដោយស្ថិរភាព និងលក្ខណៈស្ថាបនាដល់ពិភពលោក ។ នៅក្នុងកិច្ចសន្ទនានោះ ឯកឧត្តម **ស៊ី ជីនពីង** បានលើកឡើងនូវចំណុចសំខាន់ៗមួយចំនួន ដូចជា៖ **១**-យើងគួរបញ្ចេញសម្លេងប្រកបដោយភាពយុត្តិធម៌ និងសច្ចភាព ជំរុញសហគមន៍អន្តរជាតិ ឲ្យអនុវត្តពហុភាគីនិយមដ៏ពិតប្រាកដ គាំពារ

ប្រព័ន្ធអន្តរជាតិដែលចាត់ទុក អង្គការសហប្រជាជាតិជាស្នូល និងសណ្តាប់ធ្នាប់អន្តរជាតិដែលចាត់ទុកច្បាប់អន្តរជាតិជាមូលដ្ឋាន ហើយជំនួស «រង្វង់តូច» នៃអនុត្តរភាពនិយមដោយ «គ្រួសារធំ» នៃសហគមន៍រួមវាសនាតែមួយរបស់មនុស្សជាតិ **២-** យើងគួរពង្រឹងជំនឿចិត្តដែលយកឈ្នះលើការរីករាលដាលនៃជំងឺកូវីដ១៩ ប្រកាន់ខ្ជាប់អាកប្បកិរិយាទទួលខុសត្រូវ ចំពោះប្រជាជននិងអាយុជីវិត ពង្រឹងរបាំងបង្ការនិងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ ១៩ **៣-** យើងគួរប្រមូលផ្តុំកម្លាំងជំរុញការស្តារសេដ្ឋកិច្ចឡើងវិញ ធានាឱ្យខ្សែសង្វាក់ឧស្សាហកម្មនិងខ្សែសង្វាក់ផ្គត់ផ្គង់មានភាពរលូន កសាងសេដ្ឋកិច្ចសកលបែបបើកទូលាយ ដើម្បីសម្រេចកំណើនសេដ្ឋកិច្ចដែលកាន់តែប្រកបដោយភាពបរិយាប័ន្ននិងភាពធន់ និងទី**៤-** យើងគួរជំរុញការអភិវឌ្ឍជានិរន្តរភាព

តមកពីទំព័រទី ៨

និងសុខសុវត្ថិភាព។ ប្រជាពលរដ្ឋដ៏ច្រើនកុះករបានទៅបោះឆ្នោតតាមការិយាល័យនីមួយៗ ប្រកបដោយភាពថ្លៃថ្នូរ សប្បាយរីករាយ និងតាមឆន្ទៈរបស់ខ្លួន ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឱ្យបន្តដឹកនាំក្នុងមូលដ្ឋានរបស់ខ្លួន។ ការបោះឆ្នោតនេះ ត្រូវបានអ្នកសង្កេតការណ៍ជាតិ អ្នកសង្កេតការណ៍អន្តរជាតិ ក៏ដូចប្រជាជនទូទាំងប្រទេសវាយតម្លៃថា ជាការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ពិតប្រាកដ ។ ជោគជ័យនៃដំណើរការបោះឆ្នោតនេះ គឺជាសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់ប្រជាជនកម្ពុជា ក្នុងការពង្រឹងសន្តិភាព ពង្រឹងមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ និងជំរុញដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមឱ្យបានកាន់តែលឿនខ្លាំងក្លាថែមទៀតជាពិសេសការអភិវឌ្ឍនៅមូលដ្ឋាន។

ជ័យជម្នះដ៏ត្រចះត្រចង់របស់គណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នេះ កាន់តែបានបង្ហាញឱ្យឃើញច្បាស់ថា ប្រជាជនកម្ពុជាត្រូវការចាំបាច់នូវតួនាទីដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់មូលដ្ឋាន ឃុំ ភូមិ សង្កាត់។ តាមរយៈជ័យជម្នះនេះ នឹងធ្វើឱ្យគណបក្ស-ប្រជាជនកម្ពុជាមានមូលដ្ឋានកាន់តែរឹងមាំសម្រាប់ឈានទៅដណ្តើមជ័យជម្នះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅឆ្នាំ២០២៣ ខាងមុខ ហើយបានធ្វើឱ្យបរាជ័យនូវឧបាយកល និងសកម្មភាពប្រទូសរ៉ាយទាំងឡាយរបស់ពួកប្រឆាំងជ្រុលនិយម និងពួកអតីតដែលដើរផ្សំយកពីឆន្ទៈ និងផលប្រយោជន៍របស់ប្រជាជន។ ក្នុងនាមគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្តេចប្រធានកិត្តិយសគណបក្ស និងខ្លួនខ្ញុំផ្ទាល់ សូមសម្តែងការគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនសមាជិក សមាជិកាគណបក្ស យុវជន យុវនារី បងប្អូនជនរួមជាតិនៅគ្រប់ទិសទី ដែលមានជំនឿមុតមាំលើការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ហើយបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាយ៉ាងច្រើនលើសលប់ ។ ឆ្លើយតបទៅនឹងជំនឿទុកចិត្តនេះ គណបក្សសូមប្តេជ្ញាខិតខំប្រឹងប្រែងពេញទំហឹងដើម្បីអនុវត្តគោល-នយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ឆ្នាំ២០២២-២០២៧ ដែលបានប្រកាសជូនបងប្អូនជនរួមជាតិរួចហើយនោះឱ្យបានសម្រេចជោគជ័យធ្វើឱ្យឃុំ សង្កាត់នៅទូទាំងប្រទេស កាន់តែមានការរីកចម្រើនឡើងលើគ្រប់វិស័យ ប្រជាជនមានជីវភាពកាន់តែធូរធារ ហើយបន្តរស់នៅយ៉ាងសុខដុមរមនាទាំងក្នុងគ្រួសារ ក្នុងសហគមន៍ ក៏ដូចសង្គមជាតិទាំងមូល"។

សម្តេចតេជោបានគូសបញ្ជាក់ទៀតថា ៖"រយៈពេលជាងពីរឆ្នាំមកនេះ វិបត្តិនៃការផ្ទុះឡើងជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ប្រកាន់ខ្ជាប់ទស្សនៈដែលតម្កល់ប្រជាជនជាស្នូល បង្កើនការវិនិយោគលើវិស័យកាត់បន្ថយភាពក្រីក្រ ស្បៀងអាហារ ការអប់រំ និងសុខាភិបាល ជំរុញការអនុវត្តរបៀបវារៈអភិវឌ្ឍន៍ជានិរន្តរភាពឆ្នាំ២០៣០ នៃអង្គការ-សហប្រជាជាតិ ដើម្បីសម្រេចបាននូវការអភិវឌ្ឍសកល ដែលកាន់តែប្រកបដោយភាពខ្លាំងក្លា បៃតងនិងរឹងមាំ។

កិច្ចសន្ទនាជាន់ខ្ពស់នៃថ្នាក់ដឹកនាំប្រទេស«ប្រឹកបូក(BRICSPlus)» នេះ ត្រូវបានដឹកនាំដោយឯកឧត្តម **ស៊ី ជីនពីង** ប្រធានាបតីចិន ដោយមានការអញ្ជើញចូលរួមដោយប្រមុខរដ្ឋ/រដ្ឋាភិបាលមកពីប្រទេសប្រេស៊ីលរុស្ស៊ីឥណ្ឌានិងអាហ្វ្រិកខាងត្បូងប្រទេសដែលមានសេដ្ឋកិច្ចលេចធ្លោ (BRICS) និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៀត ៕

ពិភពលោកទាំងមូល ដោយពុំមានប្រទេសណាមួយអាចគេចផុតបានឡើយ ក្នុងនោះ ព្រះរាជាណាចក្រកម្ពុជាយើងក៏ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែរ។ ប៉ុន្តែដោយមានការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃ មានការចូលរួមដ៏សកម្មពីប្រជាជន និងពីគ្រប់កម្លាំងក្នុងសង្គម ព្រមទាំងការជួយឧបត្ថម្ភគាំទ្រពីសហគមន៍អន្តរជាតិ យើងអាចគ្រប់គ្រង និងដោះស្រាយវិបត្តិនេះបានយ៉ាងល្អប្រសើរ ការពារអាយុជីវិតប្រជាជនមិនឱ្យធ្លាក់ក្នុងជ្រោះមរណៈ រក្សាបានលំនឹងសេដ្ឋកិច្ច និងជីវភាពរស់នៅ ហើយបង្កភាពអនុគ្រោះឱ្យយើងអាចដំណើរការបើកប្រទេសឡើងវិញលើគ្រប់វិស័យបានចាប់ពីចុងឆ្នាំ ២០២១ មក ។ យើងមានជំនឿយ៉ាងមុតមាំថា យើងនឹងអាចជម្នះនូវផលវិបាកផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលបង្កឡើងដោយជំងឺកូវីដ-១៩ ទោះបីជំងឺនេះមិនទាន់រលាយសាបសូន្យពីផែនដីនេះក៏ដោយ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចកម្ពុជាបានវិលមកកាន់កំណើនវិជ្ជមានវិញ ហើយរំពឹងថានឹងកាន់តែមានភាពប្រសើរឡើងថែមទៀតនៅឆ្នាំ ២០២២ នេះ និងឆ្នាំ ២០២៣ ខាងមុខ។ ប៉ុន្តែ ដើម្បីបន្តយកឈ្នះលើការរាតត្បាតនៃជំងឺកូវីដ-១៩ សូមបងប្អូនជនរួមជាតិយកចិត្តទុកដាក់បន្តការពារខ្លួនតាមវិធានការសុវត្ថិភាពដែលរាជរដ្ឋាភិបាលនិងក្រសួងសុខាភិបាលបានដាក់ចេញជាពិសេសសូមអញ្ជើញទៅចាក់វ៉ាក់សាំង ដូសទី៣ ដូសទី៤ និងបន្តទៅដូសទី៥ឱ្យបានគ្រប់ៗគ្នា"។

បន្ទាប់មកតំណាងអង្គមីទ្ទិញបានឡើងអានលិខិតអបអរសាទរខួបទី៧១ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ដោយបានរំឭកឡើងវិញអំពីគុណបំណាច់ដ៏ធំធេងរបស់គណបក្ស ដែលជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការរីកចម្រើនរបស់មាតុភូមិកម្ពុជា និងបានប្តេជ្ញានូវការតាំងចិត្តដ៏មុតមាំក្នុងការគោរពគោលនយោបាយ គោលការណ៍ដឹកនាំរបស់គណបក្ស ជាពិសេសគឺបោះឆ្នោតគាំទ្រគណបក្សក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០២៣។ បន្តគាំទ្រ **សម្តេចតេជោ ហ៊ុន សែន** ជាបេក្ខជននាយករដ្ឋមន្ត្រី និងឯកឧត្តម **ហ៊ុន ម៉ាណែត** ជាអនាគតបេក្ខជននាយករដ្ឋមន្ត្រី ដើម្បីបន្តដឹកនាំមាតុភូមិកម្ពុជាឱ្យមានការអភិវឌ្ឍន៍ឆ្ពោះទៅរកភាពសម្បូរសប្បាយរុងរឿងជានិរន្តរ៍។ នៅចុងបញ្ចប់កម្មវិធីតំណាងអង្គមីទ្ទិញ តំណាងគណបក្សសម្ព័ន្ធភាព, តំណាងព្រឹទ្ធសភា, រដ្ឋសភា, គណៈរដ្ឋមន្ត្រី, តំណាងរាណសិរ្ស តំណាងខ្មែរឥស្លាម, រាជធានីភ្នំពេញ, តំណាងកាកបាទក្រហមកម្ពុជា, តំណាងយុវជន យុវនារី ទូតនៃបណ្តាប្រទេសជាមិត្តក៏បានអញ្ជើញឡើងជូនកន្ត្រកផ្កា ជាកិច្ចគោរពជូនពរជ័យដល់សម្តេចដែលជាថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ក្នុងស្មារតីសាមគ្គីភាពដ៏ស្និតរមួត។

សម្តេចតេជោ ហ៊ុន សែន ៖ វ៉ាក់សាំងអាចចាត់ទុកជានិមិត្តរូប នៃសាមគ្គីជាតិ និងឯកភាពជាតិរបស់យើង

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាព ចែកសញ្ញាបត្រជូនសិស្សសាលាភូមិន្ទរដ្ឋបាលជាង ២៣ន់នាក់

✵ នៅព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីបិទ និងប្រគល់សញ្ញាបត្រក្នុងវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០-២០២១ និងបើកវគ្គបណ្តុះបណ្តាល ឆ្នាំ២០២២ របស់សាលាភូមិន្ទរដ្ឋបាល នៅមជ្ឈមណ្ឌលសន្ទិសីទ និងពិព័រណ៍ជ្រោយចង្វារ រាជធានីភ្នំពេញ។ **សម្តេចតេជោ ហ៊ុន សែន** បានមាន ប្រសាសន៍ថា បើយើងចង់ធ្វើកំណែទម្រង់ស្ថាប័នមួយឲ្យទទួលបានជោគជ័យមុនដំបូង គឺត្រូវនិយាយពីធនធានមនុស្សសិន។ ការធ្វើឱ្យមានកំណែទម្រង់មានច្រើន ប៉ុន្តែបើចង់ឱ្យស្ថាប័នមួយទៅមុខ មានការអភិវឌ្ឍ ចំណុចសំខាន់ជាងគេ គឺការបណ្តុះបណ្តាលកែទម្រង់ធនធានមនុស្ស ពីព្រោះមានអ្វីៗបានគឺត្រូវចាប់ផ្តើមពីមនុស្សទាំងអស់ហើយស្ថាប័នមួយដែលកែទម្រង់ បានទាល់តែមនុស្សនេះធ្វើការកែទម្រង់។ផ្ទុយទៅវិញបើស្ថានប័នមួយ អត់មានធនធានមនុស្ស គឺមិនមែនជាស្ថាប័នទេ។ "ការធ្វើកែទម្រង់តាមវិស័យមួយៗ គឺចាប់ពីមានធនធានមនុស្ស និងការធ្វើកំណែទម្រង់ធនធានមនុស្ស"។

សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា ពេលនេះ កម្ពុជាទើបតែឈ្នះសមរភូមិកូវីដ១៩ប៉ុណ្ណោះតែសង្ត្រាមប្រឆាំងកូវីដ១៩ទាំងមូល កម្ពុជាមិនទាន់ឈ្នះនៅឡើយទេ មានន័យថា សង្ត្រាមប្រឆាំងជាមួយ កូវីដ១៩ មិនទាន់ចប់ទេ ប៉ុន្តែសមរភូមិដែលតា អាល់ហ្វា និងអូមីក្រុង យើងគ្រប់គ្រងបានហើយ។ ស្ថានភាពនេះអំណោយផលសម្រាប់យើង ក្នុងការបើកដំណើរការឡើងវិញនូវគ្រប់ផ្នែកទាំងអស់ ដែលយើងធ្លាប់ធ្វើនៅមុនពេលកូវីដ១៩ បានមកដល់ ក៏ប៉ុន្តែត្រូវធ្វើតាមរបៀបគន្លងថ្មី។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា រាជរដ្ឋាភិបាលបានគិតគូរណាស់ ចំពោះសិទ្ធិរស់រានមានជីវិត ជាក់ស្តែងយុទ្ធសាស្ត្រនៃការចាក់ថ្នាំបង្ការជំងឺកូវីដ១៩។ បើគ្មានសិទ្ធិរស់រានមានជីវិតហើយ គឺគ្មានអ្វីទាំងអស់ អ្នកខ្លះគេមិនហ៊ាននិយាយពីសិទ្ធិរស់រានមានជីវិតនោះទេ បែរទៅនិយាយពីសិទ្ធិអ្វីផ្សេង ប៉ុន្តែរាជរដ្ឋាភិបាលគិតគូរទាំងអស់ រាប់ទាំងសិទ្ធិបោះឆ្នោតដែលទើបកន្លងមកប៉ុន្មានសប្តាហ៍នេះ ។ សម្តេចតេជោ បានបញ្ជាក់ទៀតថា វ៉ាក់សាំងនៅកម្ពុជាអត់មានការរើសអើងនោះទេ បើទោះបីជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ មានគណបក្ស ១៧ ចូលរួម ហើយគណបក្សទាំងអស់ក៏មានសំឡេងឆ្នោតដែរ គ្រាន់តែមានចំនួនតិច និងច្រើន។ ចំណុចនេះ យើងសួរថា តើអ្នកបោះឆ្នោតទាំងនោះបានទទួលចាក់វ៉ាក់សាំងឬអត់? ចំណុចនេះ ត្រូវបានគេមើលឃើញចំពោះចំណាត់ការរបស់កម្ពុជា ទោះបីជាមានជំនឿលើសាសនាខុសគ្នា មានជំនឿលើបក្សនយោបាយខុសគ្នា ក៏ប៉ុន្តែយើងមានតម្រូវការដូចគ្នា គឺការរស់រានមានជីវិត និងការមិនឱ្យឆ្លងជំងឺកូវីដ១៩ ដូចនេះ វ៉ាក់សាំងអាចចាត់ទុកជានិមិត្តរូបនៃសាមគ្គីជាតិ និងឯកភាពជាតិរបស់យើង។

សម្តេចតេជោ ហ៊ុន សែន បានធ្វើការកត់សម្គាល់ថា រាល់ពេលដែលមានបញ្ហាណាមួយកើតឡើង តែងតែលេចចេញមុខមាត់មន្ត្រី ២ បែបគឺមន្ត្រីល្អ និងមន្ត្រីមិនបានការ។ មន្ត្រីល្អភាគច្រើនជួយដោះស្រាយបញ្ហាប្រជាពលរដ្ឋតាមមូលដ្ឋាន នៅនឹងកន្លែងជាមុនសិន ទើបរាយការណ៍មកថ្នាក់លើ សុំយោបល់ និងអន្តរាគមន៍។ ប៉ុន្តែសម្រាប់មន្ត្រីមិនបានការវិញ គឺចេះតែរាយការណ៍ទៅថ្នាក់លើឱ្យជួយដោះស្រាយបញ្ហា និងស្តីបន្ទោសថ្នាក់ក្រោមខ្លួនប៉ុណ្ណោះ។ សម្តេចតេជោ សង្កត់ធ្ងន់ថា «ធ្វើជាមន្ត្រីបើមិនចាត់ទុកការបម្រើប្រជាពលរដ្ឋ ជាគោលដៅ មិនបាច់មកធ្វើជាមន្ត្រីទេ» ។ ដើម្បីសម្រេចការងារមួយបាន ត្រូវឈរលើដំណាក់កាលចំនួនបីរួមមាន ការរៀបចំគោលនយោបាយផែនការ ការចាត់តាំងអនុវត្ត និងការដោះស្រាយលើកត្តាចៃដន្យដែលលេចឡើងពេលអនុវត្ត។ ការលេចឡើង នៃកត្តាចៃដន្យក្នុងការអនុវត្តផែនការនឹងធ្វើឱ្យលេចឡើងមន្ត្រីចំនួនពីរប្រភេទ គឺមន្ត្រីល្អប្រឹងប្រែងដោះស្រាយបញ្ហា និងមន្ត្រីមិនល្អចេះត្រឹមស្តីបន្ទោសឱ្យថ្នាក់ក្រោម និងរាយការណ៍ប៉ុណ្ណោះ ។ ដូច្នេះធ្វើជាមន្ត្រីល្អ ត្រូវគិតថា ប្រជាពលរដ្ឋជាចៅហ្វាយនាយរបស់ខ្លួន បម្រើប្រជាពលរដ្ឋឱ្យអស់ពីចិត្ត និងស្មោះត្រង់ជាមួយប្រជាពលរដ្ឋជានិច្ច ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា យើងនឹងមានការដំឡើងប្រាក់បៀវត្សរ៍មន្ត្រីរាជការ ដែលនឹងចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៣ បន្ទាប់ពីខកខានអស់រយៈពេលពីរឆ្នាំ។ យើងនឹងរៀបចំដំឡើងជូនមន្ត្រីរាជការ ប៉ុន្តែមិនគិតជាភាគរយទេ បានសេចក្តីថា អ្នកដែលមានប្រាក់ខែតិច ឡើងបានច្រើនជាងអ្នកដែលមានប្រាក់ខែខ្ពស់ ឡើងតិចជាង។ គ្រូបង្រៀន និងគ្រូពេទ្យ ទាបបំផុតឱ្យបាន១លាន៥សែនរៀល ដែលកន្លងមកគឺ១លាន៣សែនរៀល។ ក្រៅពីគ្រូបង្រៀន និងគ្រូពេទ្យ មន្ត្រីរាជការផ្សេងទៀត ដែលមានប្រាក់ខែ ១លាន២សែនរៀល នឹងដំឡើង ១លាន ៤សែនរៀល ។ សម្តេចតេជោ ក៏បានស្នើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យគិតពីពិដាននៃប្រាក់ប្រៀវត្សរ៍ជាប់ពន្ធ នៅពេលដែលតម្លើងបៀវត្សរ៍ ដោយអ្នកដែលមានប្រាក់ប្រៀវត្សរ៍ក្រោម ១,៥ លានរៀល អត់ជាប់ពន្ធទេ ប៉ុន្តែអ្នកលើសនឹងគឺជាប់ពន្ធ។

✵ នៅព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាន

អធៅទំព័រទី ៣១

ខួបលើកទី៤៥ ទិវាការចងចាំដំណើរឆ្ពោះទៅកាន់ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត

សម្តេចតេជោ ហ៊ុន សែន ៖ សន្តិភាពដែលបានកើតឡើងកន្លងមកនេះ គឺក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា

សម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម ផាម មិញជីញ នាយករដ្ឋមន្ត្រីវៀតណាម អញ្ជើញក្រោពួខួបលើកទី៤៥ នៃទិវាការចងចាំដំណើរឆ្ពោះទៅកាន់ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត និងសម្ពោធសមិទ្ធផលនានា

✵ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Phạm Minh Chính នាយករដ្ឋមន្ត្រីវៀតណាមបាន អញ្ជើញជាអធិបតី ក្នុងពិធីរំឭកខួបលើកទី៤៥ ទិវាការចងចាំដំណើរឆ្ពោះទៅកាន់ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០ មិថុនា ១៩៧៧-២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានានៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម X16 ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ក្នុងឱកាសរំលឹកទិវាជាប្រវត្តិសាស្ត្រនេះ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងអំណរគុណដល់នាយករដ្ឋមន្ត្រីវៀតណាម ដែលអនុញ្ញាតឲ្យសម្តេចបានអញ្ជើញទៅអុចធូប និងថ្លែងអំណរគុណពលរដ្ឋវៀតណាម ដែលបានជួយសម្តេចកាលពី៤៥ឆ្នាំមុន ក្នុងដំណើរទៅស្វែងរកកម្លាំងដើម្បីរំដោះប្រជាជនកម្ពុជាពីរបប ប៉ុល ពត។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កាលពីរយៈពេល ៤៥ឆ្នាំមុន ដំណើរតស៊ូរំដោះជាតិ សម្តេចមានជំរើសមួយចំនួន ដែលសម្តេចត្រូវសម្រេចជ្រើសរើស តែអ្វីដែលសម្តេចបានជ្រើសរើសនាពេលនោះ គឺត្រូវឆ្លងដែនចូលទៅកាន់ប្រទេសវៀតណាមដោយខុសច្បាប់ ដើម្បីសុំអន្តរាគមន៍ជំនួយគាំទ្រផ្នែកប្រដាប់អាវុធ ដើម្បីរំដោះប្រជាជនកម្ពុជាពីរបបអាវខ្មៅឃោរឃៅយង់ឃ្នងនោះ។ កាលពីអំឡុង ៤៥ឆ្នាំមុននោះ គឺជាការសម្រេចចិត្តស្លាប់-រស់ដែលយើងមិនមានជម្រើសល្អជាងនោះឡើយ។ សម្តេចតេជោបញ្ជាក់ថា «អ្វីៗត្រូវចាប់ផ្តើមនៅទីនេះ គឺតំបន់កោះថ្ម-X-16»នេះ ។

សម្តេចតេជោ ហ៊ុន សែន បានធ្វើការបញ្ជាក់ថា បើគ្មាន២០ មិថុនា ១៩៧៧ក៏គ្មាន១២ឧសភាឆ្នាំ ១៩៧៨ ហើយក៏ពុំមាន២ធ្នូ ឆ្នាំ ១៩៧៨ដែរ ។ ព្រោះអ្វី? អង្គការចាត់តាំងខាងយោធារបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលជាចលនាសម្រាប់ឈានឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត ត្រូវចាប់ផ្តើម កសាងអង្គភាពរៀបរយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងទៀតថា ថ្ងៃទី ២០ ខែមិថុនាឆ្នាំ ១៩៧៧ ពោលគឺ៤៥ ឆ្នាំមុនជាថ្ងៃដែលសម្តេច និងយុទ្ធមិត្តរួមអាវុធ ៤រូប បានរួមគ្នាយកជីវិតធ្វើដើមទុនចេញទៅកាន់ប្រទេសវៀតណាមស្វែងរកការគាំទ្រ ដើម្បីតស៊ូរំដោះជាតិ និងប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ដ៏ឃោរឃៅរបស់ពួកខ្មែរក្រហម។ ក្រោយព្រឹត្តិការណ៍នេះ ក៏មានព្រឹត្តិការណ៍បង្កើត «កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា» នៅថ្ងៃទី១២ ឆ្នាំ ឧសភាឆ្នាំ១៩៧៨ និងព្រឹត្តិការណ៍បង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៨។ សម្តេចតេជោបានពន្យល់ថា «ផ្លូវបត់នៃការធ្វើដំណើរឆ្ពើមចេញពីថ្ងៃ២០ មិថុនា ឆ្នាំ១៩៧៧ វាទៅចាប់ផ្តើមកកើតជាមួយនឹងកងកម្លាំងប្រដាប់អាវុធសាមគ្គី សង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី១២ ឧសភា ឆ្នាំ១៩៧៨ នោះហើយគឺជាមូលដ្ឋានដ៏សំខាន់មួយដើម្បីផ្តុំជាមួយអង្គការចាត់តាំងខាងនយោបាយនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា»។ សម្តេចតេជោបានដាក់ឈ្មោះថា «កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា»ដែលកងកម្លាំងប្រដាប់អាវុធនេះបានចេញធ្វើសកម្មភាពនៅស្រុកមេមត់ ស្រុកស្នួល រហូតចូលជ្រៅទៅដល់ស្រុកតំបែរ ។ គាប់ជួនក្នុងខែឧសភា ១៩៧៨ សម្តេច ហេង សំរិន, សម្តេច ជា ស៊ីម បះបោរឡើងនៅភាគបូព៌ាប្រទេស ហើយភាគីទាំងអស់ក៏បានចាប់ដៃគ្នាដើម្បីពង្រីកកម្លាំងតស៊ូ និងប្រមូលផ្តុំជាមួយកម្លាំងតស៊ូដទៃទៀត ឈានទៅបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ តាមរយៈថ្ងៃ២ ធ្នូ ឆ្នាំ១៩៧៨ នៃការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិនោះហើយដែលបានឈានទៅរំដោះប្រទេសនៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩។ បងប្អូនមួយចំនួនបានដឹងហើយ ប្រវត្តិសាស្ត្រក៏បានកត់ត្រាទុកអំពីអន្តរាគមន៍របស់កងទ័ពវៀតណាមដើម្បីសង្គ្រោះប្រជាជន និងប្រទេសកម្ពុជា ចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត។

សម្តេចតេជោ ហ៊ុន សែន បានចោទជាសំនួរថា តើការអន្តរាគមន៍របស់កងទ័ពវៀតណាមចូលមកជួយរំដោះប្រជាជនកម្ពុជាត្រូវឬខុស? **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា ជោគជ័យនៃការកាត់ទោសខ្មែរក្រហមគឺជាការផ្តល់យុត្តិធម៌ដល់កម្លាំងតស៊ូរបស់កម្ពុជា ដែលមានការគាំទ្រពីកងទ័ពស្មគ្រចិត្តវៀតណាម។ វៀតណាមមិនមែនដកកងទ័ពចេញពី

កម្ពុជាក្រោយកិច្ចព្រមព្រៀងប៉ារីសទេ។ វៀតណាមបានដកទ័ពចេញទាំងស្រុងពីកម្ពុជានៅថ្ងៃទី៣០ខែកញ្ញាឆ្នាំ១៩៨៩គឺមានរយៈជាង២ឆ្នាំមុនកិច្ចព្រមព្រៀងប៉ារីស ។ យើងបានប្រឹងប្រែងកសាងកម្លាំងដោយខ្លួនឯងបើទោះបីជាក្រោយការដកកងទ័ពវៀតណាមភូមិសាស្ត្រមួយចំនួនត្រូវបាត់បង់ដូចជាប៉ៃលិនអន្លង់វែងនិងតំបន់ខ្លះក៏ដោយចុះក៏ប៉ុន្តែយើងទប់ទល់បានសភាពការណ៍ ហើយទិដ្ឋភាពអន្តរជាតិនៃបញ្ហាកម្ពុជាក៏ត្រូវបានបញ្ចប់។ ព្រោះដំណោះស្រាយនយោបាយសម្រាប់បញ្ហាកម្ពុជាមានទិដ្ឋភាពពីរ គឺទិដ្ឋភាពផ្ទៃក្នុង និងទិដ្ឋភាពអន្តរជាតិ។ ពេលដែលកងទ័ពវៀតណាមដកចេញពីកម្ពុជាទិដ្ឋភាពអន្តរជាតិត្រូវបានបញ្ចប់នៅសល់តែទិដ្ឋភាពផ្ទៃក្នុងតែប៉ុណ្ណោះ ដែលផ្តល់ឱកាសឲ្យកម្ពុជាសម្របសម្រួលគ្នាតាមរយៈការចូលរួមពីភាគីពាក់ព័ន្ធរាប់ទាំងសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ នេះគឺជាចំណុចប្រវត្តិសាស្ត្រដែលយើងគួរអម្លឹក, មិនមែនដូចអ្នកខ្លះលើកថា ដោយស្មារតីកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានជាវៀតណាមដកទ័ពនោះទេ។ នេះជាការផ្សំយស្រឡះជាមួយនឹងសភាពការណ៍ជាក់ស្តែងដែលបានកើតនៅក្នុងទឹកដីកម្ពុជា ។ បើនិយាយពីជំនាញការវៀតណាមវិញ បានដកនៅថ្ងៃទី ២ ខែមិថុនា ឆ្នាំ ១៩៨៨ មុនកងទ័ពវៀតណាមដកចេញ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សន្តិភាពបានកើតឡើងរយៈពេលជាង ៤៣ឆ្នាំមកហើយ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា។ រយៈពេល ៤៣ឆ្នាំនេះ កម្ពុជាបានធ្វើកិច្ចការជាច្រើនជាមួយវៀតណាម ក្នុងនោះសម្រេចការបោះបង្គោលព្រំដែន ៨៤% ខណៈដែលចំណុចសេសសល់ ១៦%ទៀត កំពុងដំណើរការជាបន្តបន្ទាប់ដោយឈរលើទស្សនវិស័យព្រំដែនសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង។ ត្រង់ចំណុចនេះ **សម្តេចតេជោ ហ៊ុន សែន** បានបញ្ជាក់ថា៖ ខ្ញុំគ្មានសិទ្ធិដើម្បីប្រគល់ដីឲ្យវៀតណាមសូម្បីមួយ មីល្លីម៉ែត្រ ហើយខ្ញុំក៏មិនចង់បានដីវៀតណាម សូម្បីមួយមីល្លីម៉ែត្រដែរ សូមឲ្យតែត្រូវទៅតាមក្បួនខ្នាតដែលអាណានិគមនិយមបារាំងបានបន្សល់ទុកទៅបានហើយ។ សម្តេចតេជោបានបញ្ជាក់បន្តថា ក្រោយពេលអនុវត្តដោយជោគជ័យនយោបាយឈ្នះ-ឈ្នះ សម្តេចបានដាក់ចេញនូវទិសដៅពីរសំខាន់ ១-ប្រែក្លាយតំបន់អតីតសមរភូមិទាំងអស់ឲ្យទៅជាតំបន់អភិវឌ្ឍ ២-ប្រែក្លាយខ្សែបន្ទាត់ព្រំដែនជាមួយនឹងប្រទេសជិតខាងទាំងអស់ឲ្យក្លាយជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ។

សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា គោលដៅរបស់សម្តេច គឺកែប្រែតំបន់ព្រំដែនកម្ពុជា-វៀតណាម ទៅជាតំបន់សន្តិភាពនិងអភិវឌ្ឍ។ សម្តេចបានចុះហត្ថលេខា បង្កកដីនៅតំបន់ X16 ជាង១ពាន់ហិកតា ដើម្បីធ្វើជាតំបន់ពាណិជ្ជកម្ម និងស្នើឱ្យបង្កលក្ខណៈងាយស្រួលដល់ប្រជាជនកម្ពុជា និងវៀតណាម ចូលទស្សនាទៅវិញទៅមកតំបន់ប្រវត្តិសាស្ត្រ X16 ដោយមិនចាំបាច់ប្រើប្រាស់លិខិតឆ្លងដែន។ សម្តេចតេជោបានឲ្យដឹងថា ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះតំបន់ព្រំដែនកម្ពុជា-វៀតណាមនៃតំបន់ x-16 នេះនឹងក្លាយទៅជាតំបន់សេដ្ឋកិច្ចវិនិយោគដ៏សំខាន់សម្រាប់សក្តានុពលរវាងប្រជាជន និងប្រជាជនប្រទេសទាំងពីរ នឹងធ្វើឲ្យសេដ្ឋកិច្ចតំបន់នេះមានភាពល្អប្រសើរបន្ថែមទៀតនាពេលខាងមុខ។ សម្តេចតេជោបន្តថា៖ យើងត្រូវបំពេញការងារមួយចំនួនទាក់ទងនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធ ការបំពេញនីតិវិធីផ្ទៃក្នុង ដើម្បីឈានទៅសម្រេចបានច្រកព្រំដែនជាច្រកព្រំដែនអន្តរជាតិ។ នៅពេលបើកមាត់ច្រកតំបន់នេះហើយ នឹងធ្វើឲ្យប្រទេសទាំងពីរកាន់តែមានទំនាក់ទំនងកាន់តែជិតស្និទ្ធ និងធ្វើការជំរុញទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។

ក្នុងឱកាសអញ្ជើញធ្វើដំណើរឆ្លងកាត់ពីទឹកដីកម្ពុជា នៅខេត្តត្បូងឃ្មុំទៅកាន់ទឹកដីនៃប្រទេសវៀតណាម ដើម្បីរំលឹកអនុស្សាវរីយ៍កាលពី ៤៥ឆ្នាំមុន និងបានជួបជាមួយនឹងបងប្អូនប្រជាជនវៀតណាមផងនោះ **សម្តេចតេជោ ហ៊ុន សែន** រំឭកអនុស្សាវរីយ៍ថា បាយមួយពេលដែលប្រជាជនវៀតណាមបានផ្តល់ជូនសម្តេច និងសមមិត្តដ៏ស្មោះស្ម័គ្រចំនួន ៤រូប ផ្សេងទៀតកាលពី ៤៥ឆ្នាំមុនប្រៀបបានដូចជាអង្ករាប់លានតោននាពេលសព្វថ្ងៃនេះ ខណៈបាយមួយពេលនោះពិតជាមានគុណបំណាច់ដ៏ធំធេងដល់សម្តេចក៏ដូចជាប្រជាជនកម្ពុជាទាំងមូល។ សម្តេច និងយុទ្ធមិត្តចំនួនបួនរូបទៀត នាពេលនោះពិតជាមានការប្រថុយប្រថានិងសង្ឃឹមមានជីវិតតិចតួចណាស់ ខណៈដំណើរដ៏គ្រោះថ្នាក់នោះ គឺមានគោលបំណងចង់បានកម្លាំងរបស់ប្រទេសវៀតណាមមកសង្គ្រោះកម្ពុជាឲ្យរួចផុតពីកណ្តាប់ដៃពិឃាតដ៏ឃោរឃៅរបស់ប៉ុលពត។ សម្តេចតេជោបញ្ជាក់បន្ថែមថា បច្ចុប្បន្នទីតាំងកោះថ្ម «X16» ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំនេះ គឺជាកន្លែងប្រវត្តិសាស្ត្រ ហើយតំបន់នេះត្រូវបានសាងសង់នូវសំណង់មួយចំនួនរួចរាល់ហើយដូចជាសាលាដំណាក់, វេទិកាប្រារព្ធពិធី ,ស្រះទឹក, បន្ទប់អនាម័យ, ទីលានបាល់ទាត់,ប្រព័ន្ធរំដោះទឹកចាក់ដីបំពេញ, បំពាក់អំពូលអគ្គិសនីបំភ្លឺជាដើម។ **សម្តេចតេជោ ហ៊ុន សែន** ក៏បានប្រកាសពីគោលបំណងបើកច្រកព្រំដែនកម្ពុជា-វៀតណាម នៅតំបន់កោះថ្មដើម្បីសម្រួលដល់ការធ្វើដំណើរ និងផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម។ រយៈពេល ៤៥ ឆ្នាំ បានកន្លងផុត ជាមួយនឹងកិច្ចការជាច្រើនបានវិវឌ្ឍន៍រវាងប្រទេសទាំងពីរ ដោយចំណងមិត្តភាពកាន់តែស៊ីជម្រៅ និងបានធ្វើកិច្ចការជាច្រើនជាផលប្រយោជន៍កម្ពុជា-វៀតណាម។ **សម្តេចតេជោ ហ៊ុន សែន** បានបន្តថា ហេដ្ឋារចនាសម្ព័ន្ធ ដែលបានតភ្ជាប់នៅតំបន់កោះថ្ម ក៏ត្រូវបានអភិវឌ្ឍន៍។ សម្តេច និងនាយករដ្ឋមន្ត្រីវៀតណាម នៅថ្ងៃក្រោយក្នុងពេលវេលាសមស្របអាចនឹងបើកច្រកនេះទៅជាច្រកអន្តរជាតិមួយ។ ការបើកច្រកទ្វារអន្តរជាតិនេះ ត្រូវបំពេញការងារមួយចំនួនទាក់ទិននឹងការកសាងហេដ្ឋារចនាសម្ព័ន្ធ ការបំពេញនីតិវិធីផ្ទៃក្នុង ដើម្បីឈានទៅសម្រេចបើកច្រកព្រំដែន ដែលជាច្រកច្រកព្រំដែនអន្តរជាតិមួយ ដែលនឹងធ្វើឲ្យប្រទេសទាំងពីរ មានទំនាក់ទំនងកាន់តែជិតស្និទ្ធ ជាមួយនឹងច្រកពាណិជ្ជកម្ម ដែលប្រទេសទាំងពីរកំពុងមានការកើនចម្រើនយ៉ាងខ្លាំង ។ **សម្តេចតេជោ ហ៊ុន សែន** ក៏បានអរគុណដល់រដ្ឋាភិបាលវៀតណាមដែលបានសហការក្នុងកិច្ចការងារនេះអរគុណដល់បងប្អូនប្រជាពលរដ្ឋវៀតណាមសម្រាប់អនុស្សាវរីយ៍នៅពេលកន្លងមក។

ជាមួយគ្នានេះ ឯកឧត្តម **ផាម មិញ្ញឺញ** នាយករដ្ឋមន្ត្រីវៀតណាមបានរំលឹកថា ការដែលវៀតណាមបញ្ជូនកងទ័ពមកជួយកម្ពុជា ដើម្បីរំដោះខ្លួនចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត គឺផ្តើមចេញពីប្រពៃណីសាមគ្គី និងការជួយគ្នាទៅវិញទៅមក។ ចាប់តាំងពីឆ្នាំ១៩៤៥ អង្គភាពវៀតណាមជាច្រើនបានមកកម្ពុជាដើម្បីជួយកសាងកងទ័ពដែលជាកម្លាំងដើមនៃបដិវត្តន៍កម្ពុជា ហើយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានរំដោះរាជធានីភ្នំពេញ ។ ប៉ុន្តែនៅពេលនោះ កម្ពុជាមិនទទួលបានសុខសន្តិភាពទេ ហើយបានធ្លាក់ចូលទៅក្នុងសោកនាដ្ឋនកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលជាឧក្រិដ្ឋកម្មមិនអាចអត់អោនឲ្យបាន ដែល ៤ទសវត្សរ៍ក្រោយមកតុលាការពិសេសកម្ពុជាបានផ្តន្ទាទោស

សម្តេចក្រឡាហោម ស ខេង ណែនាំឱ្យអាជ្ញាធរមូលដ្ឋាន មានចំណាក់ចំនងល្អ ជាមួយប្រជាពលរដ្ឋ

សម្តេចក្រឡាហោម ស ខេង អញ្ជើញក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តពោធិរង្សី ស្រុកកញ្ចៀច ខេត្តព្រៃវែង

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ណែនាំឱ្យអាជ្ញាធរមូលដ្ឋានត្រូវផ្សារភ្ជាប់ទំនាក់ទំនងល្អ ជាមួយប្រជាពលរដ្ឋ ក្នុងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ដោយទទួលយកនូវរាល់សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋតាមរយៈវេទិកាសាធារណៈ ព្រមទាំងអនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីធានាបាននូវសុខសុវត្ថិភាព និងភាពសុខសាន្ត ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ ការណែនាំនេះ បានធ្វើឡើងនៅក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តពោធិរង្សី ស្រុកកញ្ចៀច ខេត្តព្រៃវែង នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២។

សម្តេចក្រឡាហោម ស ខេង បានសំដែងការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋាន និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃខេត្តព្រៃវែង ដែលបានខិតខំអស់ពីកម្លាំងកាយ និងស្មារតី ចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម បានល្អប្រសើរនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា ៖ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានដាក់ចេញនូវវិធានការទប់ស្កាត់យ៉ាងមានប្រសិទ្ធភាព

នូវការឆ្លងរីករាលដាលជំងឺកូវីដ១៩ ដោយរាជរដ្ឋាភិបាល បានផ្តល់នូវវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស ដែលអាចធ្វើឲ្យប្រទេសជាតិបើកដំណើរការសេដ្ឋកិច្ច និងសង្គមឡើងវិញ បង្កលក្ខណៈសម្បត្តិងាយស្រួល ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ។

សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ទៀតថា ៖ វត្តអារាមបានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមជាតិយើង ដោយក្នុងនោះ បានអប់រំប្រជាពលរដ្ឋឲ្យកសាងតែអំពើល្អ អំពើជាកុសល ដែលនាំឲ្យភូមិឃុំសហគមន៍របស់យើងទទួលបាននូវភាពសុខសាន្ត៕

យ៉ាងធ្ងន់ធ្ងរចំពោះអំពើនេះ។

ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាមបានថ្លែងថា ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ពួកខ្មែរក្រហមក៏បានជាន់ឈ្លីតម្លៃមិត្តភាព សាមគ្គីភាពដ៏ល្អរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម។ ជាការពិតនៅកម្ពុជាមានការបះបោរពីកម្លាំងតស៊ូ ពីប្រជាពលរដ្ឋនៅក្នុងតំបន់ភូមិភាគបស្ចឹមភូមិភាគល្បាសាន ភូមិភាគ៣០២ ជាដើម។ ក្នុងគ្រាដ៏លំបាកលំបិននោះ **សម្តេចតេជោ ហ៊ុន សែន** ដែលជាមេបញ្ជាការកងវរៈសេនាធំរួមជាមួយកម្មាភិបាលស្នេហាជាតិមួយចំនួនបានសម្រេចចិត្តទៅវៀតណាម ដើម្បីទទួលបានការគាំទ្រ។ ពីព្រោះនៅពេលនោះ សម្តេចតេជោបញ្ជាក់ហើយថា គ្មានប្រទេសណាអាចជួយក្រៅពីវៀតណាមនោះទេ ។ ឯកឧត្តមនាយករដ្ឋមន្ត្រីវៀតណាមបន្តថា ថ្វីបើវៀតណាមកំពុងមានការលំបាកដោយសារទើបងើបពីសង្គ្រាមប្រជាជនវៀតណាម បានបង្ហាញការចែករំលែកនូវក្តីលំបាក ដោយជួយបណ្តុះបណ្តាលកសាងកម្លាំងស្នូលកម្លាំងបដិវត្តន៍កម្ពុជា ដើម្បីប្រយុទ្ធតតាំងជាមួយប៉ុលពត ៕

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ៖ ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស គឺជាកិច្ចការដ៏សំខាន់ និងចាំបាច់រួមចំណែកដល់ការកសាងសង្គមអារ្យធម៌មួយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធអគារទីចាត់ការថ្មី

នៅព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធអគារទីចាត់ការថ្មីចំនួន ០១ខ្នង កម្ពស់២ជាន់ មាន១៥ បន្ទប់ ដែលជាអំណោយកសាងដោយ លោកឧកញ៉ា លៀង ផន និងលោកជំទាវ ឈឹម ណារី ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ**ជាស៊ីម**ជ្រោយចង្វារ សង្កាត់ជ្រោយចង្វារ ខណជ្រោយចង្វារ រាជធានីភ្នំពេញ ។ ក្នុងពិធីដ៏មហោឡារិកនេះ ក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា សមាជិករាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា អាជ្ញាធររាជធានីភ្នំពេញ ខណ្ឌ សង្កាត់ និងកងកម្លាំងមានសមត្ថកិច្ច លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ ជាច្រើនពាន់នាក់ផងដែរ។សម្តេចភក្តីសាយឈុំបានមានប្រសាសន៍ថាសមិទ្ធផលថ្មីនេះឆ្លុះបញ្ចាំងឲ្យឃើញពីតម្រូវការកាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ចំពោះការសិក្សាអប់រំរបស់សិស្សានុសិស្សនៅខណ្ឌជ្រោយចង្វារ និងការបន្តអភិវឌ្ឍជាលំដាប់របស់វិទ្យាល័យជ្រោយចង្វារ ។ ការយកចិត្តទុកដាក់ខ្ពស់របស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ពិតជាបានរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍធនធាន មនុស្សនៅខណ្ឌជ្រោយចង្វារ ក៏ដូចជារួមចំណែកពង្រឹងវិស័យអប់រំរបស់ប្រទេសជាតិទាំងមូលផងដែរ។

សម្តេចភក្តី សាយ ឈុំ បានថ្លែងបន្តថា ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស គឺជាកិច្ចការដ៏សំខាន់ និងចាំបាច់សម្រាប់រួមចំណែកដល់ការកសាងសង្គមអារ្យធម៌មួយប្រកបដោយសុខុដុមរមនាសុភមង្គល មានសណ្តាប់ធ្នាប់ និងការរីកចម្រើនជាលំដាប់ ។ បន្ទាប់ពីស្ថានភាពកូវីដ-១៩ បានធូរស្រាល ក្មួយៗ ក៏បានមករៀននៅសាលារៀនវិញជាធម្មតា ក្រោយពីអាក់ខានមិនបានរៀនដូចធម្មតាអស់រយៈជាង២ឆ្នាំមកនេះ ដោយសារការរាតត្បាតកូវីដ-១៩ ចូលក្នុងសហគមន៍របស់យើង ប៉ុន្តែទោះបីជាមិនអាចមករៀនផ្ទាល់នៅសាលាបានក៏ពិតមែន ក៏រាជរដ្ឋាភិបាលនៅតែយកចិត្តទុកដាក់ និងប្រើគ្រប់វិធីសាស្ត្រ ដើម្បីឱ្យក្មួយៗអាចសិក្សាតាមកម្មវិធីអនឡាញ តាមកម្មវិធីទូរទស្សន៍ វិទ្យុ និងតាមកម្មវិធីក្នុងទូរស័ព្ទរបស់ក្រសួងអប់រំជាដើម។ ការខិតខំទាំងអស់នេះ គឺដើម្បីធានាថាសិស្សានុសិស្សនៅតែអាចទទួលបានការបណ្តុះបណ្តាលស្របតាមកម្មវិធី និងដើម្បីរៀនសម្របខ្លួនតាមរបៀប "រស់នៅតាមគន្លងប្រក្រតីភាពថ្មី"។ **សម្តេចភក្តី សាយ ឈុំ** បានថ្លែងបន្តទៀតថា ប្រទេសកម្ពុជាយើងបានឆ្លងផុតដំណាក់កាលដ៏គ្រោះថ្នាក់ពីការវាយលុករបស់ជំងឺដ៏កាចសាហាវកូវីដ១៩រហូតឈានដល់ចំណុចជោគជ័យថ្មីមួយ ។ យើងអាចរៀបចំកម្មវិធីសម្ពោធទីចាត់ការថ្មីនេះ ដោយជួបជុំផ្ទាល់ គឺអាស្រ័យដោយកត្តាធំៗចំនួន៣ **ទី១**- រាជរដ្ឋាភិបាលគ្រប់គ្រងស្ថានការណ៍បានល្អ និងមានការដាក់ចេញផែនការនិងយុទ្ធសាស្ត្របានត្រឹមត្រូវសមស្របតាមសភាពការណ៍ជាក់ស្តែង **ទី២**- ដោយសារប្រជាជនកម្ពុជា ជាច្រើនលើសលុបចូលរួមជាមួយរដ្ឋាភិបាល គឺ ជាង ៩៤% នៃប្រជាជន ១៦លាននាក់ បានចាក់វ៉ាក់សាំងការពារ ជំងឺកូវីដ-១៩ និងមួយចំនួនធំបានចាក់ដូសជំរុញ ក្នុងនោះក៏មានអ្នកបានចាក់

ដល់ដូសទី៥ រួចទៅហើយដែរ និង**ទី៣**- ប្រជាពលរដ្ឋចូលរួមអនុវត្តវិធានការណ៍៣កុំ ៣ការពារ ដោយម៉ត់ចត់។ ជោគជ័យនេះ បានធ្វើឲ្យរាជរដ្ឋាភិបាលសម្រេចបើកប្រទេសលើគ្រប់វិស័យឡើងវិញតាំងពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០២១ មកម្ល៉េះ។ សម្តេចភក្តីបន្តថា តាំងពីបើកប្រទេសឡើងវិញមក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាព និងដោយប្រយ័ត្នប្រយែង ដើម្បីធានាបានថា ទោះបីជំងឺកូវីដ-១៩មិនទាន់រលាយបាត់ទៅវិញក៏ដោយវិធានការដែលដាក់ចេញមកនៅតែមានសុពលភាព ដែលអនុញ្ញាតឱ្យសាលារៀននៅតែបន្តបើកបង្រៀនជាធម្មតាក្រោមទស្សនាទាន **"គន្លងប្រក្រតីភាពថ្មីនៃវិស័យអប់រំ"**។

សម្តេចភក្តី សាយ ឈុំ បានថ្លែងថា ជានិច្চកាល រាជរដ្ឋាភិបាលតែងតែផ្តល់អាទិភាពទី១លើការអភិវឌ្ឍធនធានមនុស្សដើម្បីលើកស្ទួយនិងអភិវឌ្ឍវិស័យអប់រំកម្ពុជា ពោលគឺបន្តធានានូវសេវាអប់រំ ដែលមានគុណភាព ប្រកបដោយសមធម៌ និងបរិយាប័ន្ន ព្រមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំនឹងបន្តដោះស្រាយរាល់ការខ្វះខាតក្នុងវិស័យអប់រំនេះទៅតាមកំណើននៃសិស្សានុសិស្ស មិនថាតែនៅទីក្រុង ឬតាមទីជនបទឡើយ។ អាស្រ័យហេតុនេះ សូមអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បន្តផ្សារភ្ជាប់ឱ្យកាន់តែជិតស្និទ្ធជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ជាពិសេសមេឃុំ-ចៅសង្កាត់ និងថ្នាក់ដឹកនាំឃុំ-សង្កាត់ត្រូវតែរួមគ្នាឲ្យកាន់តែសកម្មជាងទៀតក្នុងការបម្រើប្រជាជននៅ តាមមូលដ្ឋានរបស់ខ្លួននិមួយៗតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនដោយគ្មានលក្ខខ័ណ្ឌ៕

ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត៖ គណបក្សប្រជាជនតម្កល់ផលប្រយោជន៍ជាតិ និងប្រជាជនជាធំ ក្រោមឆ្នុចមហាសាមគ្គីភាពជាតិ និងដំបូលនៃសុខសន្តិភាព

*ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** អញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយក្រុមការងារ យុវជនគណបក្សខេត្ត ក្រុង-ស្រុក និងក្រុមសកម្មជនយុវជនគណបក្ស ឃុំ-សង្កាត់ សាខាមន្ទីរ-អង្គភាព វិទ្យាល័យ អនុវិទ្យាល័យ និងសកម្មជន យុវជនភូមិ នៅទូទាំងខេត្តត្បូងឃ្មុំ*

នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយក្រុមការងារយុវជនគណបក្សខេត្ត ក្រុង-ស្រុក និងក្រុមសកម្មជនយុវជនគណបក្សឃុំ-សង្កាត់ សាខាមន្ទីរ-អង្គភាពវិទ្យាល័យ អនុវិទ្យាល័យ និងសកម្មជនយុវជនភូមិ នៅទូទាំងខេត្តត្បូងឃ្មុំ។ ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** បានបង្ហាញក្តីសោមនរីករាយយ៉ាងក្រៃលែងចំពោះ ការចូលរួមរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា នៃក្រុមការងារយុវជន និងសកម្មជនយុវជនយ៉ាងច្រើនកុះករជាង ២.០០០ នាក់ ដែលសុទ្ធសឹងជាក្បាលម៉ាស៊ីននៃយន្តការយុវជនរបស់គណបក្សខេត្ត។ នេះគឺជាការបង្ហាញនូវកិត្យានុភាព ជំនឿជឿជាក់ និងកម្លាំងដ៏ស្វាហាប់របស់មហាគ្រួសារគណបក្សប្រជាជនកម្ពុជានៅក្នុងខេត្តត្បូងឃ្មុំ។ ឯកឧត្តមបណ្ឌិត បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងប្រកបឆន្ទៈលះបង់ និងស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រុមការងារយុវជន និងសកម្មជនគណបក្សខេត្តត្បូងឃ្មុំ នៅក្នុងការបំពេញតួនាទី និងភារកិច្ច រហូតសម្រេចបាននូវសមិទ្ធផល និងស្នាដៃការងារជាច្រើនគួរទីមោទនៈជាអាទិ៍ ការពង្រឹងរចនាសម្ព័ន្ធ-អង្គការចាត់តាំង ស្របទៅនឹងសំណូមពរភារកិច្ចចំពោះមុខរបស់យុវជនគណបក្ស ក្នុងបរិបទបច្ចុប្បន្ននៃវឌ្ឍនភាពទៅមុខរបស់កម្ពុជាទាំងផ្នែកសង្គម និងនយោបាយ, ការងារកសាងកម្លាំងសមាជិកបក្សក្នុងនាមជាសេនាធិការឱ្យគណៈកម្មាធិការបក្សខេត្ត និងការចូលរួមបំពេញការងារមនុស្សធម៌ និងការចិញ្ចឹមចលនាសមាជិកនៅមូលដ្ឋាន ជាពិសេសការជំរុញឱ្យសមាជិកបក្ស និងប្រជាពលរដ្ឋទៅទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានយ៉ាងលើសលប់ រហូតធ្វើឱ្យខេត្តត្បូងឃ្មុំ ក៏ដូចជាប្រទេសកម្ពុជាទាំងមូលសម្រេចបាននូវភាពសុំាក្នុងសហគមន៍ ដែលនាំមកដល់ការបើកដំណើរប្រទេសឡើងវិញលើគ្រប់វិស័យ។

ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** បានគូសបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរបានផ្តល់ទំនុកចិត្តទទួលយកការចាក់វ៉ាក់សាំង ក្នុងក្របខ័ណ្ឌនៃយុទ្ធនាការជាតិ រហូតដល់ជាង ៩០% នៃចំនួនប្រជាជនសរុប ១៦ លាននាក់។ យើងសង្ឃឹមថា នៅក្នុងការបោះឆ្នោតឃុំ-សង្កាត់សម្រាប់ឆ្នាំ២០២២នេះ ក៏ដូចជាការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០២៣ ខាងមុខ គណបក្សប្រជាជនកម្ពុជា ដែលបានដឹកនាំប្រទេស និងជួយសង្គ្រោះអាយុជីវិតប្រជាជន ឆ្លងផុតពីគ្រោះភ័យវិបត្តិនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវ ក៏នឹងបន្តទទួលបាននូវការគាំទ្រ និងការជឿជាក់ពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើនលើសលប់លើសពី ៩០% ដូចជោគជ័យនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងផងដែរ ដើម្បីផ្តល់ឱកាសឱ្យគណបក្សប្រជាជនបន្តទទួលរែកពន់អម្រែកភារកិច្ចបម្រើការពារជាតិ និងប្រជាជនឱ្យបានរស់នៅក្នុងសេចក្តីសុខ សុភមង្គល និងសុវត្ថិភាពក្រោមម្លប់នៃសន្តិភាព រក្សាលំនឹងស្ថិរភាពផ្នែកសង្គមសេដ្ឋកិច្ច និងនយោបាយ ព្រមទាំងឱកាសនៃការអភិវឌ្ឍរីកចម្រើនជានិច្ចនិរន្តន៍។ ឯកឧត្តមបានបន្តថា លទ្ធផលនៃការបោះឆ្នោតនីមួយៗ គឺជាការបញ្ជាក់អំពីឥទ្ធិពលរបស់គណបក្ស និងការគោរពស្រឡាញ់ពិតប្រាកដរបស់ប្រជាជន មកលើគណបក្សនយោបាយ ដោយហេតុថា ការបោះឆ្នោតដាច់ខាតត្រូវធ្វើឡើងដោយសម្ងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលពិតជាការឆ្លុះបញ្ចាំងនូវឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋ។ ការបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាបន្តដឹកនាំ គឺជាការផ្តល់រង្វាន់ និងការគាំទ្រលើកទឹកចិត្តដល់អ្នកដែលបានខិតខំធ្វើ និងលះបង់ជាក់ស្តែង ដើម្បីឱ្យថ្នាក់ដឹកនាំ និងមន្ត្រីបក្សគ្រប់ជាន់ថ្នាក់ មានកម្លាំងចិត្ត និងលទ្ធភាពបំពេញភារកិច្ចឱ្យកាន់តែប្រសើរឡើងថែមទៀត។ ឆ្លងតាមមូលដ្ឋានស្នាដៃ និងសមិទ្ធផលជាច្រើន ដែលបានកសាងក្នុងរយៈពេលជាង ៤០ ឆ្នាំ កន្លងមកនេះ គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សតំណាងឱ្យអនាគត, ភាពត្រជាក់ជុំរុបរួមផ្សះផ្សារជាតិ និងការអភិវឌ្ឍរីកចម្រើន ដោយខុសផ្ទុយស្រឡះពីការធ្វើនយោបាយបែបប្រជាភិថុតិ ដែលនាំមកនូវសង្គ្រាមបែកបាក់, ការរើសអើង, ការបំផ្លិចបំផ្លាញ និងភាពអន់ថយ ដូចអ្វីដែលកម្ពុជាធ្លាប់បានឆ្លងកាត់រួចមកហើយក្នុងប្រវត្តិអតីតកាលដ៏ជូរចត់ ៕

សកម្មភាពសមាជិកព្រឹទ្ធសភា-រដ្ឋសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ **សម្តេចពិជ័យសេនា ទៀ បាញ់** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងារគណបក្សចុះ មូលដ្ឋានខេត្តសៀមរាប អញ្ជើញដឹកនាំក្បួនបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅខេត្តសៀមរាប។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ខេត្តស្វាយរៀង បានអញ្ជើញជាអធិបតីក្នុង ពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅតាមបណ្តាក្រុង/ស្រុកទាំង៨ ក្នុងខេត្តស្វាយរៀង ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា ឯកឧត្តមប្រធានគណបក្សខេត្តស្វាយរៀង ឯកឧត្តម លោកជំទាវ ក្រុមការងារគណបក្សចុះជួយ ឃុំ សង្កាត់ ក្នុងខេត្តស្វាយរៀង គណៈកម្មាធិការគណបក្សខេត្ត គណៈកម្មាធិការគណបក្ស ឃុំ សង្កាត់ ព្រមទាំងសមាជិក សមាជិកា យុវជន ចំនួន ៣៣.២២០នាក់ នៅស្នាក់ការគណបក្សឃុំស្វាយជ្រំ ខេត្តស្វាយរៀង។

ថ្ងៃទី០៣ខែមិថុនាឆ្នាំ២០២២ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិក-គណៈអចិន្ត្រៃយ៍គណៈ កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ បានអញ្ជើញជាអធិបតីក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ឯកឧត្តមថ្លែងថា គណបក្សប្រជាជនកម្ពុជា គឺជារបស់ប្រជាជន កើតឡើងស្ថិតស្ថេរីកចម្រើនដោយសារប្រជាជន និងធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីផលប្រយោជន៍ដ៏ឧត្តុង ឧត្តមរបស់ប្រជាជន និងប្រទេសជាតិ ។ ចាប់តាំងពីពេលបដិសន្ធិ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ គណបក្សប្រជាជនកម្ពុជាបានប្រកាន់ខ្ជាប់ឥតប្រែប្រួលនូវគោលបំណង និងឧត្តមគតិរបស់ខ្លួន គឺរួមសុខរួមទុក្ខជាមួយប្រជាជនគ្រប់កាលៈទេសៈ ពុះពារជម្នះគ្រប់ឧបសគ្គ ហ៊ានពលិកម្ម ឥតរួញរា ដើម្បីប្រទេសកម្ពុជា និងប្រជាជន។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកលើកដែក បានអញ្ជើញជាអធិបតីក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដោយមានការចូលរួមយ៉ាងច្រើនកុះករពីថ្នាក់ដឹកនាំក្នុងជួរសមាជិកគណៈអចិន្ត្រៃយ៍បក្សក្រុង-ស្រុក សមាជិកគណៈកម្មាធិការ គណបក្សក្រុង-ស្រុកមន្ត្រីថ្នាក់ដឹកនាំក្រុមការងារគណបក្សចុះមូលដ្ឋានក្រុង-ស្រុកក្រុមការងារគណបក្សចុះតាមឃុំ-សង្កាត់ និងសមាជិកសមាជិកា ស្ត្រី យុវជនគណបក្សប្រជាជនកម្ពុជា មកពីគ្រប់បណ្តាឃុំក្នុងស្រុកលើកដែក សរុបមានចំនួនប្រមាណជាង ៥ ពាន់នាក់ នៅស្រុកលើកដែក ខេត្តកណ្តាល។

សកម្មភាពសមាជិកព្រឹទ្ធសភា-រដ្ឋសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិក គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តកណ្តាល និងជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ចុះមូលដ្ឋានស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងស្រុកកៀនស្វាយ បានអញ្ជើញដឹកនាំគណៈប្រតិភូ និងសមាជិកជាង៣៥.០០០នាក់ ដង្ហែក្បួនបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។



ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការ ដឹកនាំនៃគណៈកម្មាធិការភាពជាដៃគូសកលនៃការសំអាត និងទឹកស្អាត សម្រាប់ ទាំងអស់គ្នា (Sanitation and Water for All) ក្នុងនាមជាគណៈកម្មការដឹកនាំ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក តាមរយៈប្រព័ន្ធវីដេអូអនឡាញ។

ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តកំពង់ធំ បានអញ្ជើញដឹកនាំសមាជិក សមាជិកាគណបក្សបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដោយមានអ្នកចូលរួមជាង ១ម៉ឺននាក់ជាមួយនឹងការហែក្បួនដ៏ឱឡារិកអធិកអធមគគ្រឹកគគ្រេង ដែលបង្ហាញកាន់តែច្បាស់ពីប្រៀបខ្លាំង ប្រៀបឈ្នះទាំងខាងកម្លាំង ទាំងខាងស្មារតីសតិអារម្មណ៍របស់គណបក្សប្រជាជនកម្ពុជាយ៉ាងពិតប្រាកដ និងបានអំពាវនាវដល់សមាជិកបក្ស និងប្រជាពលរដ្ឋទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ជោង ខុន** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធានទី១ ក្រុមការងារគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ និងជាប្រធានក្រុមការងារចុះជួយស្រុកបារាយណ៍ និងស្រុកតាំងគោក បានអញ្ជើញដឹកនាំសមាជិកគណបក្សបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ឆ្នាំ២០២២ នៅស្រុកបារាយណ៍ ដែលមានអ្នកចូលរួមជាង ១.៥០០នាក់ និងស្រុកតាំងគោក មានអ្នកចូលរួមជាង ១.៥០០នាក់ដែរ ។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ង៉ែត សូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និងឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង និងលោកជំទាវ បានអញ្ជើញជាអធិបតីក្នុងពិធីបិទបញ្ចប់យុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា ក្រុមការងារគណបក្សចុះជួយមូលដ្ឋានស្រុក ឃុំ ក្នុងក្របខ័ណ្ឌស្រុក គណៈកម្មាធិការគណបក្សស្រុក គណៈកម្មាធិការគណបក្សឃុំ ព្រមទាំងសមាជិក សមាជិកា យុវជន គណបក្ស ចំនួន ៦ពាន់នាក់ ដង្ហែក្បួននៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

សកម្មភាពសមាជិកព្រឹទ្ធសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាប្រធានក្រុមការងារគណបក្សចុះជួយមូលដ្ឋានស្រុកកោះសូទិន ខេត្តកំពង់ចាម និងលោកជំទាវ រួមជាមួយសមាជិក សមាជិកា គណបក្សបានអញ្ជើញចូលរួមហែក្បួនបិទបញ្ចប់យុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅតាមបណ្តាឃុំទាំង ៨ នៃស្រុកកោះសូទិន ខេត្តកំពង់ចាម។

ថ្លែងទៅកាន់ប្រជាពលរដ្ឋនិងសិស្សានុសិស្សប្រមាណ ២០០០នាក់ នៅក្នុងពិធី **"ទិវាជាតិនៃការចងចាំ ២០ឧសភា"** ដែលបានប្រារព្ធឡើងកាលពីព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ នៅក្នុងឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ឯកឧត្តម **ង្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានគូសបញ្ជាក់ថា: ប្រវត្តិសាស្ត្រកម្ពុជាបានឆ្លងកាត់អតីតកាលនៃសោកនាដកម្មមិនអាចបំភ្លេចបាននៅក្នុងសង្គ្រាមនិង របបប្រល័យ ពូជសាសន៍។ ការចងចាំនេះមានតម្លៃសម្រាប់មនុស្សគ្រប់រូប និងគ្រប់ជំនាន់ ពិសេសគឺយុវវ័យ។ ហេតុនេះ **យើងត្រូវចងចាំអតីតកាលដើម្បីកសាងអនាគតរុងរឿងរបស់កម្ពុជា**។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **អ៊ុត សំហេង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញចូលរួមពិធីបិទបញ្ចប់យុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដោយមានសមាជិក សមាជិកា របស់គណបក្សប្រជាជនកម្ពុជាសង្កាត់ទាំង១២ នៃខណ្ឌចំការមន និងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ម៉ែន សុីម៉ន** សមាជិកគណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះមូលដ្ឋានខេត្តកំពត រួមជាមួយ ឯកឧត្តមបណ្ឌិត **ហៅ ចនិន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពត បានអញ្ជើញជាអធិបតីក្នុងពិធីបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅក្នុងទីរួមខេត្តកំពត។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកកណ្តាលស្ទឹង រួមជាមួយឯកឧត្តម **ណុប រតនៈ** អនុប្រធានក្រុមការងារគណបក្ស ចុះមូលដ្ឋានស្រុកកណ្តាលស្ទឹង ព្រមទាំងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាស្រុកកណ្តាលស្ទឹងរាបពាន់នាក់ បានអញ្ជើញចូលរួមក្នុងពិធីបិទយុទ្ធនាការ ឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

សកម្មភាពសមាជិកវរជួសតា-ព្រឹទ្ធសតា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ស៊ុន ចាន់ថុល** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារចុះមូលដ្ឋានស្រុកកោះធំ ខេត្តកណ្តាល បានអញ្ជើញដឹកនាំក្រុមការងារសមាជិកសមាជិកាយុវជន និងសកម្មជនគណបក្សប្រជាជនកម្ពុជាក្នុងស្រុកកោះធំ បិទបញ្ចប់យុទ្ធនាការឃោសនាកសំឡេងឆ្នោត សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ជិត ៧ ពាន់នាក់ ដង្ហែក្បួនតាមផ្លូវជាតិ និងចុះទៅតាមឃុំនានានៅទូទាំងស្រុកកោះធំ ខេត្តកណ្តាល ប្រកបដោយភាពមហោឡារិកជាទីបំផុត។

ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុនធាង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត និងទទួលជួយស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រធានគណៈកម្មការទី១០ និងជាអ្នកនាំពាក្យព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលការងារជាមួយក្រុមប្រឹក្សាឃុំត្រពាំងវែង រួមជាមួយប្រជាការពារភូមិ ឃុំ ដឹកនាំដោយលោកស្រី **យ៉ា សារឿន** ប្រធានក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋានការថែរក្សាសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយសាធារណៈជូនប្រជាពលរដ្ឋ ស្ថិតនៅសាលាឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ឯកឧត្តមក៏បានឧបត្ថម្ភថវិកាជូនដល់ក្រុមប្រឹក្សាឃុំចំនួន ៦៥.៨០០.០០០រៀល សម្រាប់បម្រើឱ្យការអភិវឌ្ឍភូមិ ឃុំ និងរៀបចំអាហារការងារដល់អាជ្ញាធរមូលដ្ឋានពិសេសបងប្អូនប្រជាការពារ ដែលតែងតែយកកម្លាំងកាយចិត្ត និងពេលវេលា ថែរក្សាសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ ។

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ស្សោច សារ៉ាត** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សខេត្តព្រៃវែង និងលោកជំទាវ ព្រមទាំងឯកឧត្តម លោកជំទាវ សមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត គណៈអភិបាលក្រុង កងកម្លាំងទាំង ៣ ប្រធានអនុប្រធានមន្ទីរ/អង្គភាពនានាជុំវិញខេត្ត បានរៀបចំប្រារព្ធពិធីបួងសួង សុំសេចក្តីសុខ សេចក្តីចម្រើន ជូនដល់មន្ត្រីរាជការ កងកម្លាំងទាំង ៣ ប្រជាពលរដ្ឋទូទាំងខេត្ត នៅទីទួលស័ក្តសិទ្ធ បារមីលោកយាយបារាយណ៍អណ្តែត ។

ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០២២ ឯកឧត្តម **ជាម ប៉ែអ** អ្នកតំណាងរាស្ត្រ និងជាអនុប្រធានទី១ ក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកស៊ីធរកណ្តាល តំណាងឲ្យឯកឧត្តម **កន សុខន** ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកស៊ីធរកណ្តាល បានដឹកនាំកិច្ចប្រជុំ **"បូកសរុបវាយតម្លៃការងារបោះឆ្នោតក្រុមប្រឹក្សាឃុំអាណត្តិទី៥ ឆ្នាំ២០២២"** ក្នុងបរិយាយកាសរីករាយ និងអបអរសាទរលទ្ធផលបោះឆ្នោតមានសំឡេងគាំទ្រកើនឡើងលើសលប់ទាំង១១ឃុំ។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះក្រុមការងារដែលខិតខំប្រឹងប្រែងសហការគ្នាស្វែងយល់ពីសុខទុក្ខប្រជាពលរដ្ឋ និងជួយដោះស្រាយការលំបាកជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានជាប្រចាំ។

ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឃួង ស្រេង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជារាជធានី បានដឹកនាំក្បួនបិទយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលមានការជួបជុំនៅមហាវិថី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** (ផ្លូវ ៦០ម៉ែត្រ) ក្នុងសង្កាត់ចាក់អង្រែខណ្ឌមានជ័យដោយមានប្រជាពលរដ្ឋមន្ត្រីរាជការគ្រប់ស្រទាប់វណ្ណៈ និងសមាជិកបក្សចូលរួមប្រមាណជាង ៣ម៉ឺននាក់៕

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្ស ថ្នាក់កណ្តាល បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីសំណេះសំណាល ជាមួយក្រុមជំនួយការលេខាធិការដ្ឋាន និងបណ្តាផ្នែកចំណុះ នៃយុវជនគណបក្ស ថ្នាក់កណ្តាល ដែលមានការចូលរួមពីថ្នាក់ដឹកនាំយុវជនគណបក្ស ថ្នាក់កណ្តាល និងក្រុមជំនួយការលេខាធិការដ្ឋាន និងបណ្តាផ្នែកចំណុះ នៃយុវជនគណបក្ស ថ្នាក់កណ្តាល សរុបចំនួន ៣ ០០០រូប នៅទីស្នាក់ការកណ្តាល គណបក្សប្រជាជនកម្ពុជា(វិមាន ៧មករា) ។

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្ស ថ្នាក់កណ្តាល បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្ស ថ្នាក់កណ្តាល ប្រកាសប្រគល់ភារកិច្ច និងកែសម្រួល តែងតាំងមន្ត្រីយុវជនគណបក្ស ថ្នាក់កណ្តាល ដោយមានការចូលរួមចំនួន ២៤រូប នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា(វិមាន ៧មករា)។

ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ជ្រុន ថេ៉ាឌ៉ាត** សមាជិកគណៈកម្មាធិការកណ្តាល ជាអនុប្រធានយុវជនគណបក្ស ថ្នាក់កណ្តាល និងជាប្រធានជនបង្គោលយុវជនថ្នាក់កណ្តាលចុះជួយស្រុកព្រៃឈរ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ហ៊ុន ម៉ាណែត** បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីជួបជុំជាមួយបេក្ខជនពេញសិទ្ធិក្រុមប្រឹក្សាឃុំទាំង ១១៥រូបទូទាំងស្រុកព្រៃឈរខេត្តកំពង់ចាមដើម្បីអបអរសាទរជ័យជម្នះនៃការបោះឆ្នោតនិងសម្តែងនូវការអរគុណ ដែលមានការចូលរួមពី អនុប្រធាន សមាជិក សមាជិកា ក្រុមការងារជនបង្គោល ក្រុមការងារថ្នាក់ស្រុក រួមជាមួយនឹងក្បាលម៉ាស៊ីនដឹកនាំយុវជន និងក្រុមសកម្មជនយុវជនគ្រប់បណ្តាថ្នាក់ សរុបចំនួន ៣៦៦រូប នៅទីស្នាក់ការគណបក្សស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ហួត ហាក់** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្ស ថ្នាក់កណ្តាល និងជាប្រធានក្រុមការងារជនបង្គោលយុវជនថ្នាក់កណ្តាល ចុះជួយស្រុកចំការលើ ខេត្តកំពង់ចាម ដោយបានកិច្ចសហការពីប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយឃុំចំការអណ្តូង ប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាស្រុក និងក្រុមជនបង្គោលទទួលការងារយុវជនប្រចាំស្រុកចំការលើ បានអនុវត្តតាមផែនការសកម្មភាពការងាររបស់ ឯកឧត្តមប្រធាន **ហ៊ុន ម៉ានិត** បានចុះជួបបងប្អូនប្រជាពលរដ្ឋនៅតាមផ្ទះក្នុងឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម។



